ឆ្នាំទី៨ លេខ៨៦ ខែកុម្ភៈ ឆ្នាំ២០២០

# ព្រឹត្តិបត្រ

# កៅស៊ូធម្មជាតិ

# Natural Rubber Bulletin

ផ្សាយចេញពី អគ្គនាយកដ្ឋានកៅស៊ូ





## ១.អាគសញ្ញាជំងឺក្រៀមខ្លោកន្ទុយស្លឹក ២.ការសម្អាតនិងធ្វើផ្លូវភ្លើង





ផ្លូវជាតិលេខ៦អា ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៦៧២២ ៥៩០ E-mail: gdr.maff@gmail.com

## នាយកបណ្ណាធិការ

- ឯកឧត្តម **ប៉ុល សុផា**

## គណៈកម្មាធិការបណ្ណាធិការ

- លោក **ឃុន កក្កដា** ប្រធាន
- លោក **ហ៊ន សាផន** អនុប្រធាន
- លោក **គុយ ភក្តី** អនុប្រធាន
- កញ្ញា **ថូ ស្រីស** សមាជិកអចិន្ត្រៃយ៍
- លោក **លួង សុខខេង** សមាជិក
- លោក **គូរ ផល្លី** សមាជិក
- លោក **គង់ ថា** សមាជិក
- លោក **ព្រៃ សុភាព** សមាជិក
- លោក **ញាណ សុភា** សមាជិក
- លោកស្រី **ស្វាយ ណាបុល** សមាជិក
- លោក **សូ សុវណ្ណា** សមាជិក
- លោក **តូ ប៊ុនធី** សមាជិក

## ការីកុំព្យូទ័រ

- លោក **ឈួង ឈី**
- កញ្ញា **ថូ ស្រីស**

## ការីទំនាក់ទំនងនិងបោះពុម្ព

- លោក **គុយ ភក្តី**
- អ៊ីម៉ែល៖ phokpheakdey@yahoo.com
- ទូរស័ព្ទ៖ ០១៦ ២៩៣ ៤២៣

## Editor-in-chief

- H.E. Pol Shopha

## Editorial Board

| | |
|---|---|
| Mr. Khun Kakada | Director |
| Mr. Horn Saphan | Vice Director |
| Mr. Kuy Pheakdey | Vice Director |
| Ms. Tho Srey Sor | Permanent Member |
| Mr. Loung Sokheng | Member |
| Mr. Kou Phally | Member |
| Mr. Kong Tha | Member |
| Mr. Prey Sopheap | Member |
| Mr. Nhean Sophea | Member |
| Mrs. Svay Nabol | Member |
| Mr. So Sovanna | Member |
| Mr. Tou Bunthy | Member |

## Computer Operator

- Mr. Choung Chhy
- Ms. Tho Srey Sor

## Contact & Publication

- Mr. Kuy Pheakdey
- E-mail: phokpheakdey@yahoo.com
- Tel: 016 293 423

# បទវិចារណកថា

*ប្រិយមិត្តទាំងអស់ជាទីមេត្រី!*

ស្ថានភាពផលិតកម្មនិងធុរកិច្ចកៅស៊ូធម្មជាតិកម្ពុជាប្រចាំខែកុម្ភៈ ឆ្នាំ២០២០បានបង្ហាញថា៖ ផ្ទៃដីកៅស៊ូសរុបមានចំនួន៤០៥ ៤៨៥ហិកតា ដែលក្នុងនោះផ្ទៃដីចៀរជ័រចំនួន២៥០ ៧៥០ហិកតា ស្មើនឹង ៦២% និងផ្ទៃដីថែទាំចំនួន១៥៤ ៧៣៥ហិកតា ស្មើនឹង៣៨%។ បរិមាណផលិតសរុបក្នុងខែកុម្ភៈ មានចំនួន១៣ ២៤៦តោន បានថយចុះចំនួន១៥ ៩៥៧តោន (-៥៥%) បើធៀបនឹងខែមុន និងថយចុះចំនួន ១០ ៥៥៨តោន (-៤៤%) ធៀបនិងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។ រហូតដល់ខែកុម្ភៈ (២ខែដើមឆ្នាំ ២០២០) បរិមាណផលិតសរុបមានចំនួន៤២ ៤៤៩តោន បានថយចុះចំនួន៥ ៦៤៦តោន (-១២%) ធៀបនិងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។ បរិមាណបញ្ចេញលក់ក្នុងខែកុម្ភៈ ឆ្នាំ២០២០មានចំនួន១៣ ៨៦២តោន បានថយចុះចំនួន១៣ ៥៨៣តោន (-៤៩%) ធៀបខែមុន ប៉ុន្តែបានកើនឡើងចំនួន៨១៨តោន(+៦%) ធៀបនិងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។ បរិមាណបញ្ចេញលក់រហូតមកដល់ខែកុម្ភៈ (២ខែឆ្នាំ២០២០) មានចំនួន៤១ ៣០៦តោន បានកើនឡើងចំនួន៤ ៨១២តោន (+១៣%) ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៩ និងសន្និធិចុងគ្រាចំនួន១៨ ២៨៦តោន។ តម្លៃលក់មធ្យមក្នុងខែកុម្ភៈ ឆ្នាំ២០២០ ស្មើនឹង១ ៤១៤ US$/តោន បានថយចុះ១៩US$/តោន (=-១,៣៣%) បើធៀបនឹងខែមុន ប៉ុន្តែបានកើនឡើង១១៤ដុល្លារ/តោន(=+៩%) ធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។ តម្លៃលក់ជាមធ្យមរហូតមកដល់ខែកុម្ភៈ ឆ្នាំ២០២០ ស្មើនឹង១ ៤២៦US$/តោន បានកើនឡើង១៧៤US$/តោន(=+១៤%) បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ស្ថានភាពទិញជ័រកៅស៊ូគ្រួសារតាមតំបន់នានាប្រចាំខែកុម្ភៈនេះ មានតម្លៃចន្លោះពី៤ ៦០០ ទៅ ៤ ៨២៥៛/គ.ក្រ សម្រាប់ជ័រស្ងួត និង២ ០៧៥ - ២ ៥៦៣៛/គ.ក្រ សម្រាប់ជ័រកក។ ជារួម តម្លៃទិញ-លក់ជ័រកៅស៊ូគ្រួសារបានកើនឡើងពី១០០៛/គ.ក្រ អាស្រ័យតាមតំបន់ បើធៀបនឹងខែមុន។

យោងរបាយការណ៍ប្រចាំខែកុម្ភៈ ឆ្នាំ២០២០ របស់សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC) បានបង្ហាញឲ្យឃើញថា៖ ផលិតផលកៅស៊ូពិភពលោកប៉ាន់ស្មានសម្រាប់ឆ្នាំ២០២០ មានចំនួន ១៤,១៧៧តោន ប៉ុន្តែនឹងធ្លាក់ចុះប្រមាណ៥,២% ពីផលិតផលសរុបប្រចាំឆ្នាំ ក្នុងអឡុងខែមករា - កុម្ភៈនេះ។ បរិមាណប្រើប្រាស់កៅស៊ូធម្មជាតិពិភពលោកនឹងមានចំនួន១៣,៨២៤លានតោន ប៉ុន្តែនឹងធ្លាក់ចុះ ១៨,៦%វិញ ដោយសារតែ ការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោកបណ្តាលមកពីការឆ្លងរាលដាលយ៉ាងធ្ងន់ធ្ងររហូតដល់៩០ប្រទេស នៃCOVID19 រួមនឹងស្ថានភាពទ្រឹងនៃឧស្សាហកម្មកមន្តសាលក្នុងប្រទេសចិនក្នុងរយៈពេល២ខែដំបូងក្នុងឆ្នាំ២០២០។

ចំពោះ និន្នាការតម្លៃកៅស៊ូធម្មជាតិចាប់ពីពាក់កណ្តាលខែមករារហូតមក កំពុងគ្របដណ្តប់ដោយការព្រួយបារម្ភអំពីផលប៉ះពាល់នៃវីរុសកូរ៉ូណាទៅលើសេដ្ឋកិច្ចពិភពលោក ក៏ដូចជាទៅលើតម្រូវការប្រើប្រាស់កៅស៊ូធម្មជាតិផងដែរ។ ទីផ្សារហ៊ុនបានដាំក្បាលចុះនៅចុងខែកុម្ភៈ ហើយពួកវិនិយោគិនរក្សាស្ថាន-ភាពស្ងៀមស្ងាត់នឹងកំពុងតាមដានមើលវិបត្តិនៃសេដ្ឋកិច្ចពិភពលោក ដែលបណ្តាលមកពីការរីករាលដាលនៃវីរុសកូរ៉ូណា។ កំណើនសេដ្ឋកិច្ចពិភពលោករំពឹងថានឹងធ្លាក់ចុះ២% មកនៅត្រឹម១%ប៉ុណ្ណោះ ទន្ទឹមពេលដែលមុខទំនិញពាណិជ្ជកម្មទីផ្សារហ៊ុន និងពួកវិនិយោគិនរក្សាភាពស្ងប់ស្ងាត់ ដែលនឹងមិនអាចធ្វើឲ្យតម្លៃកៅស៊ូធម្មជាតិរឹងមាំបានទេនៅក្នុងរយៈពេលខ្លី។ ស្ថានភាពទីផ្សារពិភពលោករំពឹងថា នឹងមានភាពប្រសើរឡើងវិញចាប់ពីចុងត្រីមាសទី១ឆ្នាំ២០២០។

ក្រុមការងារព្រឹត្តិបត្រកៅស៊ូធម្មជាតិនៃអគ្គនាយកដ្ឋានកៅស៊ូនឹងនៅតែបន្តយកចិត្តទុកដាក់តាមដានពីគ្រប់មជ្ឈដ្ឋានប្រភពព័ត៌មាន ដើម្បីផ្តល់ជូនខ្លឹមសារនិងរូបភាពកាន់តែច្បាស់ថែមទៀតអំពីស្ថានភាពវិវឌ្ឍនិន្នាការទីផ្សារនិងទស្សនវិស័យនៃឧស្សាហកម្មកៅស៊ូធម្មជាតិសម្រាប់រយៈពេលខ្លី មធ្យម និងវែង ទាំងក្នុងក្របខណ្ឌជាតិ តំបន់ និងពិភពលោក។ ជាមួយគ្នានេះ ក្រុមការងារយើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្ររបស់សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក/អ្នកឧកញ៉ា និងមិត្តអ្នកអានទាំងអស់និងរង់ចាំទទួលមតិរិៈគន់ស្ថាបនាពីគ្រប់មជ្ឈដ្ឋានដើម្បីកែលម្អព្រឹត្តិបត្រនេះឲ្យកាន់តែមានគុណភាពប្រសើរឡើងថែមទៀត៕

*សូមអរគុណ !!!*

# ព័ត៌មានក្នុងប្រទេស

## កិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅអនុវត្តការងារឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានកៅស៊ូ

ចាប់ពីថ្ងៃទី៥-៦ ខែកុម្ភៈ ឆ្នាំ២០២០ អគ្គនាយកដ្ឋានកៅស៊ូ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅអនុវត្តការងារឆ្នាំ២០២០ ក្នុងគោលបំណងសំខាន់គឺ៖ (១) ពិនិត្យឡើងវិញលើលទ្ធផលការងាររបស់អគ្គនាយកដ្ឋានកៅស៊ូដែលបានអនុវត្តក្នុងឆ្នាំ២០១៩ កន្លងមក ដើម្បីពិភាក្សារកចំណុចខ្លាំង ចំណុចខ្សោយ និងបញ្ហាប្រឈម (២)ប្រមូលធាតុចូលសំខាន់ៗ និងកាលានុវត្តភាពថ្មីៗបន្ថែមទៀតពីគ្រប់ភាគីពាក់ព័ន្ធ សម្រាប់ពង្រឹងនិងជំរុញការអភិវឌ្ឍអនុវិស័យកៅស៊ូ និង(៣)កំណត់ទិសដៅការងាររបស់អគ្គនាយកដ្ឋានកៅស៊ូដែលត្រូវអនុវត្តបន្ត ដោយអនុលោមតាមកម្មវិធីដែលបានអនុម័តសម្រេចផ្តល់ថវិកា សម្ភារៈ និងមធ្យោបាយចាំបាច់នានាសម្រាប់បំពេញការងារនៅក្នុងឆ្នាំ២០២០ និងឆ្នាំខាងមុខ។

### ១. ដំណើរការនិងលទ្ធផលនៃកិច្ចប្រជុំ

**ថ្ងៃទីមួយ៖**

នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២០ ពិធីបើកកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅអនុវត្តការងារឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានកៅស៊ូបានការអញ្ជើញចូលរួមជាគណៈអធិបតីពីសំណាក់ឯកឧត្តម **ម៉ាន សុគ្រី** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឯកឧត្តម លោក លោកស្រី ជាថ្នាក់ដឹកនាំអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លោក លោកស្រី នាងកញ្ញាជាមន្ត្រីរាជការនៃអគ្គនាយកដ្ឋានកៅស៊ូ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត តំណាងសមាគមអភិវឌ្ឍន៍កៅស៊ូកម្ពុជា សហគមន៍កសិកម្មកៅស៊ូគ្រួសារតាមតំបន់ តំណាងក្រុមហ៊ុនចម្ការកៅស៊ូកសិឧស្សាហកម្ម ម្ចាស់រោងចក្រសិប្បកម្មកែច្នៃជ័រនិងឈើកៅស៊ូ តំណាងមកពីធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម (ARDB) និង អង្គការស្បៀងអាហារនិងកសិកម្ម (FAO) សរុបមានចំនួន ១៩១នាក់។



*គណៈអធិបតីក្នុងពិធីបើកកិច្ចប្រជុំបូកសរុបការងារអគ្គនាយកដ្ឋានកៅស៊ូឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០*

ជាកិច្ចចាប់ផ្ដើម ឯកឧត្ដម **ម៉ុល សុផា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ បានថ្លែងសុន្ទរកថាស្វាគមន៍ដល់គណៈអធិបតីនិងអង្គពិធីស្ដីពីស្ថានភាពនៃការអភិវឌ្ឍកៅស៊ូធម្មជាតិនៅទូទាំងប្រទេសក្នុងឆ្នាំ២០១៩ ទោះបីជាផ្ទៃដីដំណាំកៅស៊ូមានការថយចុះបន្តិចបើធៀបនឹងឆ្នាំកន្លងទៅ ប៉ុន្តែចំណូលពីការនាំចេញកៅស៊ូគឺមានការកើនឡើងប្រមាណជាង៩០លានដុល្លារអាម៉េរិក ស្មើនឹង៣១,៥២% ដោយសារតែតម្លៃលក់ជ័រកៅស៊ូជាមធ្យមបានកើនចំនួន១៨,៦ដុល្លារអាម៉េរិក/តោន ស្មើនឹង១,១៤% បើធៀបនឹងតម្លៃមធ្យមក្នុងឆ្នាំ២០១៨។



*ឯកឧត្ដម **ម៉ុល សុផា** ថ្លែងសុន្ទរកថាស្វាគមន៍ដល់គណៈអធិបតីនិងអង្គពិធី*

ដោយឡែកចំពោះ ការងារនៅលើឆាកអន្តរជាតិវិញ កម្ពុជាបានបំពេញតួនាទីក្នុងឋានៈជាសមាជិកពេញសិទ្ធិរបស់សមាគមបណ្ដាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC: Association of Natural Rubber Producing Countries) ក្រុមប្រឹក្សាស្រាវជ្រាវកៅស៊ូអន្តរជាតិ (IRRDB: Intenational Rubber Research and Development Board) សមាគមកៅស៊ូអន្តរជាតិ (IRA: International Rubber Association) និងដៃគូសហប្រតិបត្តិការទ្វេភាគី ឬពហុភាគីក្នុងការស្រាវជ្រាវ ពិសោធន៍ ការពង្រឹងទីផ្សារ ព័ត៌មានកៅស៊ូ ការបង្កើនគុណភាពកៅស៊ូតាមស្តង់ដារអន្តរជាតិ និងការងារផ្សេងៗទៀតជាច្រើន។ ទន្ទឹមនឹងសមិទ្ធិផលដែលបានខាងលើនេះ អគ្គនាយកដ្ឋានកៅស៊ូ នៅជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចជា៖ ខ្វះលិខិតបទដ្ឋានគតិយុត្តមួយចំនួនក្នុងអនុវិស័យកៅស៊ូ ខ្វះកិច្ចសហការពីគ្រប់ភាគីពាក់ព័ន្ធ ខ្វះថវិកា មធ្យោបាយ និងធនធានមនុស្សក្នុងការអនុវត្តការងារ។

បន្ទាប់មក ឯកឧត្ដម **ម៉ាន សុគ្រី** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានថ្លែងសុន្ទរកថាបើកកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងការលើកទិសដៅការងារឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានកៅស៊ូ ដោយបានសម្ដែងនូវការកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គនាយកដ្ឋានកៅស៊ូ ដែលបានខិតខំយកអស់ស្មារតី និងកម្លាំងកាយ ចិត្ត ក្នុងការបំពេញភារកិច្ចរបស់ខ្លួនដើម្បីធ្វើឲ្យអនុវិស័យកៅស៊ូមានការរីវត្តរីកចម្រើនគួរឲ្យកត់សម្គាល់។ ទន្ទឹមនឹងនេះ ឯកឧត្ដមបានជម្រាបជូនអង្គប្រជុំទាំងមូលជ្រាបថាកន្លងមក **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា តែងតែបានរំឭកពីការរីកចម្រើននិងសក្តានុពលនៃឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជា ដោយដំណាំនេះ បានបង្កើនប្រាក់

ចំណូល បង្កើតអាជីពនៅជនបទ ជួយកាត់បន្ថយភាពក្រីក្រ និងការធ្វើចំណាកស្រុក។ បន្ថែមពីនោះ ឯកឧត្តមបានកត់សម្គាល់លើបញ្ហាប្រឈមចម្បងៗមួយចំនួនគឺ៖ លិខិតបទដ្ឋានគតិយុត្ត កិច្ចសហការក្នុងការអនុវត្តការងារ មធ្យោបាយ និងធនធានមនុស្សនៅមានកម្រិតនៅឡើយ ដែលបញ្ហាទាំងនេះចាំបាច់ត្រូវខិតខំបន្ថែមទៀតដោយមានកិច្ចសហការពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីស្វែងរកដំណោះស្រាយឲ្យបានសមស្របនិងទាន់ពេលវេលា ក្នុងគោលដៅជំរុញការអភិវឌ្ឍលើអនុវិស័យកៅស៊ូឲ្យកាន់តែមានប្រសិទ្ធភាព និងមាននិរន្តរភាព។

បន្ទាប់ពី សម្រាកពិសាអាហារសម្រន់រួចមក អង្គប្រជុំបានស្តាប់ការធ្វើបទបង្ហាញ បទអន្តរាគមន៍ និងប្រធានបទពិភាក្សារួម ជាបន្តបន្ទាប់៖

១."លទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅអនុវត្តការងារឆ្នាំ២០២០" ដោយលោក **សុខ ផូស៊ីនី** ប្រធាននាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងស្ថិតិ។

២. "និរន្តរភាពកៅស៊ូធម្មជាតិ" ដោយលោកបណ្ឌិត **អូន សុវណ្ណ** អគ្គនាយករងនៃអគ្គនាយកដ្ឋានកៅស៊ូ។

៣."យន្តការជម្រើសដើម្បីដោះស្រាយថ្លៃកៅស៊ូនៅក្នុងរយៈពេលខ្លីរបស់ ANRPC " ដោយលោក **ឃុន កក្កដា** អគ្គនាយករងនៃអគ្គនាយកដ្ឋានកៅស៊ូ។

៤."ជំងឺជ្រុះស្លឹក Pestalotiopsis" ដោយលោក **លិម ខាន់ទីវ៉ា** នាយករងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។

៥.បទអន្តរាគមន៍របស់សមាគមអភិវឌ្ឍន៍កៅស៊ូកម្ពុជា។

៦.បទអន្តរាគមន៍របស់សហគមន៍កសិកម្មកៅស៊ូគ្រួសារ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។

៧.បទអន្តរាគមន៍របស់អង្គការស្បៀងអាហារ និងកសិកម្ម (FAO)។

៨.បទអន្តរាគមន៍របស់ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម(ARDB)។

៩.ប្រធានបទពិភាក្សារួមស្តីពីយន្តការគ្រប់គ្រងរបាយការណ៍ ព័ត៌មានទិន្នន័យ ស្ថិតិកៅស៊ូ និងការផ្តល់ធាតុចូលបន្ថែមនៅក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០។

អង្គប្រជុំបានជជែកពិភាក្សាលម្អិតអំពីបញ្ហាពាក់ព័ន្ធនឹងការអភិវឌ្ឍឧស្សាហកម្មកៅស៊ូធម្មជាតិ ការធ្វើពាណិជ្ជកម្មកៅស៊ូ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា តាមរយៈ សំណូមពរ មតិយោបល់ និងបញ្ហាប្រឈមមួយចំនួនដូចជា៖

១. គាំទ្រឲ្យមានច្បាប់ស្តីពីកៅស៊ូព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាមួយចំនួនដើម្បីធានាការគ្រប់គ្រងនិងការអភិវឌ្ឍអនុវិស័យកៅស៊ូឲ្យមាននិរន្តរភាព។

២.ជំរុញការអនុវត្តសារាចរណែនាំលេខ១០ សរណន ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីអំពីវិធានការទប់ស្កាត់ការនាំចេញជ័រកៅស៊ូ និងឈើកៅស៊ូមិនទាន់កែច្នៃទៅបរទេសឲ្យមានប្រសិទ្ធភាព។

៣.ជំរុញនិងពង្រឹងសកម្មភាពដឹកនាំ គ្រប់គ្រង

សហគមន៍កសិកម្មកៅស៊ូគ្រួសារតាមតំបន់ និងជួយគាំទ្ររកប្រភពថវិកាដល់ដំណើរការរបស់សហគមន៍ឲ្យមានដំណើរដោយរលូននិងសម្រេចតាមគោលដៅដែលបានគ្រោងទុក។

៤. បន្តការចុះផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសឲ្យបានច្រើនថែមទៀតដល់កសិករក្នុងការដាំដុះ ការប្រមូលផល ការបង្កើនគុណភាពផលិតផលជ័រកៅស៊ូ។

៥.សូមទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍបន្តជួយគាំទ្រការអភិវឌ្ឍអនុវិស័យកៅស៊ូនៅកម្ពុជាតាមរយៈការផ្តល់ប្រាក់កម្ចីសម្បទាន សម្រាប់ជួយគាំទ្រដល់កសិករកៅស៊ូគ្រួសារ។

៦. សូមធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្មជួយគាំទ្រដល់សហគមន៍កសិកម្មកៅស៊ូគ្រួសារ តាមរយៈការផ្តល់ប្រាក់កម្ចីដែលមានអត្រាការប្រាក់ទាបនិងមានរយៈពេលវែង ដើម្បីពង្រឹងនូវសមត្ថភាពសហគមន៍កសិកម្មកៅស៊ូគ្រួសារឲ្យក្លាយទៅជាសហគ្រិនពេញលេញ។

បន្ថែមពីនេះ សមាជិក សមាជិកា នៃអង្គប្រជុំបានលើកជាសំណូមពរសុំឲ្យអគ្គនាយកដ្ឋានកៅស៊ូពិសេស ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជួយដូចជា៖

- ពង្រឹងនិងពង្រីកសមាគមអភិវឌ្ឍន៍កៅស៊ូនៅកម្ពុជាឲ្យបានរឹងមាំ
- សម្រួលដល់ការស្នើសុំដូរមុខដំណាំ
- អន្តរាគមន៍សម្រួលបន្ថយអត្រាពន្ធនាំចេញ
- សម្រួលនីតិវិធីដល់ការនាំចូលសម្ភារៈឧបករណ៍ បម្រើក្នុងអនុវិស័យកៅស៊ូ ថ្លៃដើមខ្ពស់លក់បានទាប
- ជួយអន្តរាគមន៍កាត់បន្ថយចំណាយក្រៅផ្លូវការក្នុងការធ្វើឯកសារនិងកានាំចេញ
- ជួយអន្តរាគមន៍កាត់បន្ថយថ្លៃសាវ៉ាធ្វើភូតគាមអានាម័យនិងការបញ្ជាក់ប្រភពដើម។

**<u>ថ្ងៃទីពីរ៖</u>**

នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២០ ពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅអនុវត្តការងារឆ្នាំ២០២០ របស់អគ្គនាយក-ដ្ឋានកៅស៊ូ បានការអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ពីសំណាក់ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអមដោយឯកឧត្តម លោក លោកស្រីជាថ្នាក់ដឹកនាំអង្គភាពក្រោមឱវាទនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លោក លោកស្រី នាងកញ្ញាជាមន្ត្រីរាជការនៃអគ្គនាយកដ្ឋានកៅស៊ូ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត តំណាងសមាគមអភិវឌ្ឍន៍កៅស៊ូកម្ពុជា សហគមន៍កសិកម្មកៅស៊ូគ្រួសារតាមតំបន់ តំណាងក្រុមហ៊ុនចម្ការកៅស៊ូកសិឧស្សាហកម្ម ម្ចាស់រោង-ចក្រសិប្បកម្មកែច្នៃជ័រនិងឈើកៅស៊ូ តំណាងមកពីធនាគារអភិវឌ្ឍន៍ជនបទនិងកិសកម្ម (ARDB) និងអង្គការស្បៀងអាហារនិងកសិកម្ម (FAO) ។



*គណៈអធិបតីក្នុងពិធីបិទកិច្ចប្រជុំបូកសរុបការងារ អគ្គនាយកដ្ឋានកៅស៊ូឆ្នាំ២០១៩ និងលើកទិសដៅ ការងារឆ្នាំ២០២០*

ជាកិច្ចចាប់ផ្តើម ឯកឧត្តម **ម៉ុល សុផា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ បានធ្វើសេចក្តីរាយការណ៍អំពីលទ្ធផល នៃកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅអនុវត្តការងារឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានកៅស៊ូ មាន៖

❖ ក្នុងឆ្នាំ២០១៩ កម្ពុជាមានផ្ទៃដីកៅស៊ូសរុបទូទាំងប្រទេសចំនួន៤០៥ ៦៧១ហ.ត ធៀបនឹងឆ្នាំ២០១៨ ដែលមានចំនួន៤៣៦ ៦៨២ហ.ត ថយចុះ៣១ ០១១ហ.ត ស្មើនឹង៧%។ ការថយចុះផ្ទៃដីនេះភាគច្រើនកើតមានលើក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចមួយចំនួនដែលបានផ្លាស់ប្តូរមុខដំណាំ ព្រោះដីមិនសមស្របនឹងដំណាំកៅស៊ូ និង ក្រុមហ៊ុនមួយចំនួនទៀតការគ្រប់គ្រងថែទាំកៅស៊ូមិនបានល្អធ្វើឲ្យមានភ្លើងឆេះនៅរដូវប្រាំង ក្នុងនោះផ្ទៃដីចម្ការកៅស៊ូកសិ-ឧស្សាហកម្មមានចំនួន២៤៤ ៥៦៨ហ.ត ស្មើនឹង៦០% និង ផ្ទៃដីចម្ការកៅស៊ូគ្រួសារមានចំនួន១៦១ ១០៣ ហ.ត ស្មើនឹង៤០%។ ផ្ទៃដីកៅស៊ូចៀរជ័រមានចំនួន២៥០ ៤៧៧ហ.ត បើធៀបនឹងឆ្នាំ២០១៨ មានចំនួន២០១ ៩៤៧ហ.ត គឺកើនឡើង៤៨ ៥៣០ហ.ត ស្មើនឹង២៤,១%។ ជាមួយនេះដែរផលិតផលកៅស៊ូសម្រេចបានចំនួន២៨៧ ៦៣៨តោន ធៀបនឹងឆ្នាំ២០១៨ មានចំនួន២២០ ១០០តោន គឺកើនឡើង៦៧ ៥៣៨តោន ស្មើនឹង៣០,៦៩%។ ទិន្នផលជាមធ្យមមានចំនួន១ ១៤៨គ.ក្រ/ហ.ត ធៀបនឹងឆ្នាំ២០១៨ មានចំនួន១ ០៩០គ.ក្រ/ហ.ត កើនឡើង៥៨គ.ក្រ/ហ.ត ស្មើនឹង ៥,៣២%។ ចំពោះ ការនាំចេញកៅស៊ូក្នុងឆ្នាំ២០១៩សម្រេចបានចំនួន២៨២ ០៧១តោន ស្មើនឹងទឹកប្រាក់ចំនួន៧ ៩៤២ ១៥១ដុល្លារអាម៉េរិក ធៀបនឹងឆ្នាំ២០១៨ ដែលមានចំនួន២៧១ ៥០០តោន គិតជាទឹកប្រាក់សរុបមានចំនួន២៨៦ ៦០៨ ១១៧ដុល្លារអាម៉េរិក បានកើនឡើងចំនួន៦៤ ៥៧១តោន ស្មើនឹង ២៩,៦៩% ដែលប្រាក់ចំណូលបានកើនឡើងប្រមាណ៩០ ៣៣៤ ០៣៤ដុល្លារអាម៉េរិក/តោន ធៀបនឹងឆ្នាំ២០១៨ដែលមានតម្លៃមធ្យមស្មើនឹង១ ៣១៧,៣៤ដុល្លារអាម៉េរិក/តោន កើនឡើងចំនួន ១៨,៦ដុល្លារអាម៉េរិក/តោន ត្រូវនឹង១,៤១%

❖ កម្ពុជាមានរោងចក្រសិប្បកម្មកែច្នៃកៅស៊ូចំនួន១៥៤កន្លែង ស្ថិតក្នុងខេត្តចំនួន១១ បានកើនឡើងចំនួន៨កន្លែង ស្មើនឹង៥,៤៤% បើធៀបនឹងឆ្នាំ២០១៨ ដែលមានចំនួន១៤៧កន្លែង។ ក្នុងចំណោមរោងចក្រសិប្បកម្មចំនួន១៥៥នេះ មានរោងចក្រកែច្នៃកៅស៊ូបញ្ជាក់តាមបច្ចេកទេស(TSR: Technically Specified Rubber) ចំនួន៤៦កន្លែង រោងចក្រកែច្នៃ

ទឹកជ័រខាប់ (CL: Concentrated Latex) ចំនួន១កន្លែង សិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយប្រើផ្សែង (RSS: Ribbed Smoked Sheet) សិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយខ្យល់ក្តៅ(ADS: Air Dried Sheet) សិប្បកម្មកែច្នៃកៅស៊ូសន្លឹក (RS: Rubber Sheet) មានចំនួន៩៦កន្លែង និងរោងចក្រកែច្នៃឈើកៅស៊ូ (RWF: Rubber Wood Factory) ចំនួន១១កន្លែង

❖ បានដំណើរការអនុវត្តសកម្មភាពទៅតាមគម្រោងថវិកាកម្មវិធីដែលមានអនុកម្មវិធីចំនួន៣ និងចង្កោមសកម្មភាពចំនួន១២ ផ្តោតជាសំខាន់នៅលើការងារផ្សព្វផ្សាយបណ្តុះបណ្តាលជំនាញបច្ចេកទេសកៅស៊ូដល់ប្រតិបត្តិករកៅស៊ូ និងការស្រាវជ្រាវពិសោធន៍។ ជារួម ការអនុវត្តគម្រោងថវិកាទទួលបានជោគជ័យជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៩នេះ ក្នុងអត្រា៩៨% នៃថវិកាដែលអនុម័ត

❖ ការងារដែលបាននិងកំពុងអនុវត្តលើការស្រាវជ្រាវពិសោធន៍ រួមមាន៖

- ធ្វើការវិភាគ DNA ក្លូនកៅស៊ូនៅលើច្បារពូជកៅស៊ូសរុបចំនួន ១២៣,៨៤ហ.ត ដែលមានសំណាកចំនួន៥ ២១៣សំណាក

- ដាំដុះក្លូនកៅស៊ូជាច្បារយោងចំនួន១,៤ហ.ត ស្មើនឹង១០០ប្លុក ស្មើនឹង២២ក្លូន និងបង្កើតច្បារពូជសមុច្ច័យ (Collection budwood garden) ចំនួន ០,៦ហ.ត

- បន្តថែទាំច្បារពូជកៅស៊ូឯកជនចំនួន១៨ច្បារពូជ ស្មើនឹង២៣,៤៤ហ.ត រហូតដល់ឆ្នាំ២០១៨ ស្ថិតនៅក្នុងខេត្តចំនួន៨ លើស្រុកចំនួន១០ ដោយផ្តល់លើវិញ្ញាបនបត្របញ្ជាក់ច្បារពូជ និងបានលើកស្លាកសញ្ញានៅតាមទីតាំងច្បារពូជទាំង១៨ រួចរាល់

- បាននិងកំពុងថែទាំចម្ការកៅស៊ូដែលដាំពិសោធន៍ស្តីពី "Effective of cover crop and fertilizer on rubber growth and prodiction" ចំនួន៥ហ.ត ៤ប្លុក

- ការងារស្រាវជ្រាវបង្កាត់ពូជ

- ការស្រាវជ្រាវសរីរវិទ្យានិងអាជីវកម្ម

- ការស្រាវជ្រាវអំពីការដាំដុះនិងការពារ

- ការងារមន្ទីរពិសោធន៍ជាតិយថាប្រភេទ (ធ្វើតេស្តវិភាគសំណាកយថាប្រភេទដើម្បីបញ្ជាក់គុណភាពការកែច្នៃរបស់រោងចក្រ) អនុវត្តការងារបច្ចេកទេសតាមប្រព័ន្ធគ្រប់គ្រង ISO 17025:2005 របស់មន្ទីរពិសោធន៍

- ការងារនៅស្ថានីយអនុវត្តមាន៖

• បើកវគ្គបណ្តុះបណ្តាលលើបច្ចេកទេសកៅស៊ូដល់កសិករ

• បើកសិក្ខាសាលាស្តីពីការផ្ទេរបច្ចេកវិទ្យាសម្រាប់ការអភិវឌ្ឍកៅស៊ូគ្រួសារ

• ទទួល និងធ្វើការណែនាំបច្ចេកទេសដល់និស្សិតសាលាជាតិកសិកម្មកំពង់ចាម និង និស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្មចុះទស្សនៈកិច្ចសិក្សានៅស្ថានីយអនុវត្ត។

❖ ការងារសហប្រតិបត្តិការអន្តជាតិរួមមាន៖

- កម្ពុជាបានចូលជាសមាជិកពេញសិទ្ធិរបស់មាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC) តាំងពីថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៩ និងបានបំពេញតួនាទីយ៉ាងសកម្មក្នុងនាមជាសមាជិករបស់សមាគម។

រហូតមកដល់បច្ចុប្បន្នសមាគមនេះ មានសមាជិកចំនួន១៣ប្រទេស គ្រប់គ្រងផលិតផលកៅស៊ូប្រមាណ ៩០% នៃផលិតផលកៅស៊ូពិភពលោក។ តាមកម្មវិធីការងារប្រចាំឆ្នាំរបស់សមាគមនេះ អគ្គនាយកដ្ឋានកៅស៊ូ ដោយមានការគាំទ្រពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តែងបញ្ជូនមន្ត្រីជំនាញចូលរួមវគ្គបណ្តុះបណ្តាលនិងកិច្ចប្រជុំនានា

- វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាបានចូលជាសមាជិកពេញសិទ្ធិទី១៦ នៃក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ (IRRDB) តាំងពីថ្ងៃទី២៧-២៨ ខែកញ្ញា ឆ្នាំ២០០១ នៅទីក្រុង Montpe-llier សាធារណរដ្ឋបារាំង ក្រុមប្រឹក្សានេះគ្រប់គ្រងផលិតផលប្រមាណ៩៥% នៃផលិតផលពិភពលោក

- ជាមួយទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) អគ្គនាយកដ្ឋានកៅស៊ូបានសហការអនុវត្តនូវគម្រោងជាបន្តបន្ទាប់ចាប់ពីឆ្នាំ១៩៩៩មក មានៈ

(១)គម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូនៅកម្ពុជាដែលបានចាប់ផ្តើមពីឆ្នាំ២០១២មក និងបានបញ្ចប់កាលពីខែសីហា ឆ្នាំ២០១៨ កន្លងទៅនេះ

(២)គម្រោងផលិតកម្មកៅស៊ូឆ្លាតខាងអាកាសធាតុតាមរយៈការជំរុញការអនុវត្តកសិកម្មល្អ "Climate Smart Rubber Production through promoting Good Agriculture Practices (GAP)" និង

(៣) គម្រោងអភិវឌ្ឍកៅស៊ូគ្រួសារនៅកម្ពុជា គម្រោងនេះ បានបញ្ចប់ការសិក្សាលទ្ធភាពដែលអាចធ្វើបានដំណាក់ការទី២នៅខេត្តគោលដៅចំនួន ២ គឺខេត្តរតនគិរី និងខេត្តបាត់ដំបងដែលចុះសិក្សាដោយក្រុមហ៊ុន GLG Consultant។ ជាលទ្ធផលនៃការចុះសិក្សាគម្រោងខាងលើតម្រូវឲ្យមានការសិក្សាគម្រោងចំនួន៣បន្ថែមទៀតរួមមានៈ (១)ការវិភាគខ្សែច្រវ៉ាក់តម្លៃនិងការប្រកួតប្រជែង (Value chain and competitiveness analysis) (២)គុណភាពនិងការនាំចេញផលិតផលកៅស៊ូ (Quality and export of rubber products) និង (៣)ការគ្រប់គ្រងអនុវិស័យកៅស៊ូ (Sector organization)ដែលគម្រោងទាំង៣នេះបានបញ្ចប់រួចរាល់ហើយដែរ។ គម្រោងអភិវឌ្ឍន៍កៅស៊ូគ្រួសារនេះមានផលប្រយោជន៍ដល់កសិករ សេដ្ឋកិច្ច សង្គម និងបរិស្ថានផងដែរ ប៉ុន្តែគម្រោងមិនអាចអនុវត្តបានព្រោះឥណទានសម្រាប់គម្រោងអភិវឌ្ឍន៍កៅស៊ូគ្រួសារនៅកម្ពុជាលើកនេះ រដ្ឋាភិបាលបារាំងតាមរយៈ AFD ផ្តល់ជាកម្ចីអធិបតេយ្យ (Sovereign Loan) ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមិនអាចទទួលឥណទាននេះទេ។

- ជាមួយភាគីចិនតាមរយៈ "កិច្ចសហប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយកម្ពុជា-ចិន" ក្រសួងកសិកម្មនៃប្រទេសទាំងពីរបានចុះអនុស្សារណៈនៃការយោគយល់គ្នាមួយស្តីពី "កិច្ចសហប្រតិបត្តិការលើវិស័យឧស្សាហកម្មកៅស៊ូធម្មជាតិ" កាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥។ បន្ទាប់មកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជានិងវិទ្យាស្ថានស្រាវជ្រាវដំណាំកសិកម្មត្រូពិចចិន (CATAS) ក៏បានចុះកិច្ចព្រមព្រៀងជាមួយគ្នា លើការស្រាវជ្រាវរួមគ្នាផងដែរ កាលថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៣ នៅទីក្រុងកូឡំបូ ប្រទេសស្រីលង្កា។ តាមរយៈកិច្ចសហការនេះ កម្ពុជាបានទទួលការបណ្តុះបណ្តាល សិក្ខា-សាលា ពិសេសបានបំពាក់ឧបករណ៍មន្ទីរពិសោធន៍

ផ្នែកក្សេត្រសាស្ត្រ លើការវិភាគថ្នាំ ដី និងស្លឹកកៅស៊ូឲ្យបានដំណើររួចហើយផងដែរ

- ជាមួយអង្គការស្បៀងអាហារនិងកសិកម្ម (FAO) អគ្គនាយកដ្ឋានកៅស៊ូបានប្រជុំពិភាក្សាពិនិត្យ និងកែសម្រួលឯកសារនៃសេចក្តីព្រាងគម្រោង កិច្ចសហប្រតិបត្តិការជាមួយអង្គការស្បៀងអាហារ និងកសិកម្ម (FAO) ដើម្បីរៀបចំគម្រោងថ្នាក់តំបន់ (Regional Project Formulation) សម្រាប់ប្រទេសកម្ពុជាដោយផ្តោតលើគម្រោងប្រព័ន្ធតាមដានចម្ការកៅស៊ូគ្រួសារ (Rubber Family Farm Monitoring System Project)

- ដោយឡែក ចំពោះគម្រោងអភិវឌ្ឍន៍កៅស៊ូក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា ឡាវ និងវៀត-ណាម (CLV DTA) អគ្គនាយកដ្ឋានកៅស៊ូបានប្រជុំ ពិនិត្យ និងពិភាក្សាកែតម្រូវនិងធ្វើបច្ចុប្បន្នភាពនូវតួលេខនិងខ្លឹមសារមួយចំនួនជាបន្តបន្ទាប់ ដែលចុងក្រោយនេះបានបញ្ជូនទៅក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ តាមរយៈលិខិតលេខ១០៦៩ អក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ហើយក្រសួងក៏បានផ្ញើរបាយការណ៍នេះបន្តទៅលេខាធិការដ្ឋាន CLV DTA នៃក្រសួងពាណិជ្ជកម្ម ដើម្បីអនុវត្តនីតិវិធីបន្តជាមួយនឹងភាគីវៀតណាមសម្រាប់ត្រៀមដាក់ជូនកិច្ចប្រជុំកំពូលលើកទី១១ ដែលនឹងរៀបចំនៅប្រទេសឡាវ ក្នុងខែមីនា ឆ្នាំ២០២០ខាងមុខ ដើម្បីសូមការយល់ព្រមរួចរាល់ហើយ

- ក្រៅពីកិច្ចសហប្រតិបត្តិការកម្រិតរដ្ឋាភិបាលខាងលើវិស័យឯកជន គឺសមាគមអភិវឌ្ឍន៍កៅស៊ូកម្ពុជា ក៏បានចូលរួមជាសមាជិកសមាគមន៍កៅស៊ូអន្តរជាតិ (IRA: International Rubber Association) និងក្រុមប្រឹក្សាធុរកិច្ចកៅស៊ូអាស៊ាន (Asian Rubber Business Council) ដែលមានសមាជិក៦ប្រទេស តាំងពីឆ្នាំ២០០៦ ផងដែរ

❖ ជាមួយនឹងការទទួលបានលទ្ធផលល្អប្រសើរក្នុងឆ្នាំ២០១៩ខាងលើនេះ ក៏នៅមានបញ្ហាប្រឈមមួយចំនួន៖

- ផលិតភាពនៅទាប

- ថ្លៃដើមផលិតកម្មខ្ពស់ តែលក់បានទាប

- ការផ្តល់និងការទទួលយកបច្ចេកវិទ្យាកៅស៊ូសមស្របដល់កសិករកៅស៊ូគ្រួសារនៅមានកម្រិត

- យន្តការគាំទ្រសហគមន៍កសិកម្មកៅស៊ូគ្រួសារនៅមានកម្រិត (ឥណទានមណ្ឌលកែច្នៃកៅ-ស៊ូនិងមណ្ឌលទីផ្សារកៅស៊ូ)

- ខ្វះអ្នកចៀរជ័រ ដោយសារតែមានការប្រកួតប្រជែងកម្លាំងពលកម្មពីវិស័យដទៃ

- ការស្រាវជ្រាវបច្ចេកវិទ្យាកៅស៊ូនិងចំនួនអ្នកជំនាញវិទ្យាសាស្ត្រនៅមានកម្រិត

- កង្វះច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធមួយចំនួន និងការអនុវត្តនៅមានកម្រិត

- លទ្ធភាពនៃការប្រមូលរបាយការណ៍ ព័ត៌មានទិន្នន័យស្ថិតិពាក់ព័ន្ធនឹងកៅស៊ូ ក៏នៅតែជាបញ្ហាប្រឈមនៅឡើយ

- ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងលំនៅដ្ឋានកម្មកររបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងក្រុមហ៊ុនមួយចំនួនមិនទាន់បានល្អសមស្រប

- ការគាំទ្រផ្នែកបច្ចេកទេស មធ្យោបាយធ្វើដំណើរ ថវិកា ធនធានមនុស្ស និងឥណទានរបស់

រដ្ឋនិងដៃគូអភិវឌ្ឍន៍នានានៅមានកម្រិត

- កិច្ចសហការរវាងអាជ្ញាធរដែនដី កងកម្លាំងមានសមត្ថកិច្ចតាមច្រកព្រំដែន និងអង្គភាពពាក់ព័ន្ធក្នុងការទប់ស្កាត់ការនាំចេញជ័រនិងឈើកៅស៊ូមិនទាន់កែច្នៃទៅបរទេសពុំទាន់មានប្រសិទ្ធភាពល្អ

- ខ្វះផ្នែកកៅស៊ូលំហូរខាងក្រោម (Rubber downstram sector) ។

ជាកិច្ចបន្ត ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានមានមតិសំណេះសំណាលនិងផ្តល់អនុសាសន៍ល្អៗដល់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានកៅស៊ូ ព្រមទាំងមន្ត្រីរាជការក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំងអស់ដែលបានចូលរួម ដើម្បីជាមាគ៌ាតម្រង់ទិសក្នុងការអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជាឲ្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ បន្ថែមពីលើនេះ ឯកឧត្តមរដ្ឋមន្ត្រី បានសង្កត់ធ្ងន់លើចំណុចមួយចំនួនដល់អង្គប្រជុំ ក៏ដូចជាអគ្គនាយកដ្ឋានកៅស៊ូឲ្យយកចិត្តទុកដាក់ពិចារណា និងអនុវត្តឲ្យបានយ៉ាងសកម្មតាមចំណុចដូចខាងក្រោម៖

១.ត្រូវធ្វើផែនការយុទ្ធសាស្ត្រអភិវឌ្ឍដំណាំកៅស៊ូឆ្ពោះទៅឆ្នាំ២០៣០ ឲ្យបានសមស្របទៅនឹងស្ថានភាពជាក់ស្តែងនាពេលអនាគតដោយមានការចូលរួមមតិយោបល់ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ ដូច្នេះត្រូវប្រមូលធាតុចូលជាចាំបាច់ឲ្យបានគ្រប់គ្រា និងត្រូវរៀបចំធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រនេះឲ្យបានចប់សម្រាប់ជាត្រីវិស័យក្នុងការអនុវត្តពេលអនាគត និងសហការជាមួយបណ្តាលក្រុមហ៊ុនដែលបានធ្វើការវិនិយោគ និងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដាំកៅស៊ូទាំងអស់រួមទាំង កៅស៊ូគ្រួសារផងដែរលើការងារបច្ចេកទេសដូចជា៖ ការដាំដុះក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ ការថែទាំ ការយកផលការកែច្នៃ ការពង្រីកវិសាលភាពនៃពិសោធន៍ទៅតាមតំបន់ដែលមានសក្តានុពលដំណាំកៅស៊ូរួមទាំងការនាំចេញឲ្យបានសមស្របតាមលក្ខខណ្ឌបច្ចេក-ទេស និងនីតិវិធីជាធរមាន

២.ត្រូវយកចិត្តទុកដាក់ខ្ពស់ចំពោះទីផ្សារនាំ-ចេញផលិតផលកៅស៊ូនាពេលអនាគត។ ត្រូវគិតគូរជាចម្បងទៅលើ៖ (១) ធានាឲ្យទីផ្សារអន្តរជាតិមានការទទួលស្គាល់ផលិតផលកៅស៊ូកម្ពុជាថាជាផលិតផលមានគុណភាពតាមស្តង់ដារត្រឹមត្រូវ ព្រមទាំងយកចិត្តទុកដាក់ធ្វើយ៉ាងណាឲ្យមានការទទួលស្គាល់តម្លៃនៃមន្ទីរពិសោធន៍របស់វិទ្យាស្ថានតាមស្តង់ដារអន្តរជាតិ (ISO) (២) ជំរុញការធ្វើពិពិធកម្មផលិតផលកៅស៊ូកែច្នៃបឋម ជាប្រភេទផលិតផលជ័រកៅស៊ូខាប់និងកៅស៊ូចម្រុះសម្រាប់ទីផ្សារដែលមានសក្តានុពលពិសេសប្រទេសចិន (៣) សិក្សាអំពីតម្រូវការនៃធនធានមនុស្ស ជំនាញបម្រើក្នុងអនុវិស័យកៅស៊ូឲ្យបានច្បាស់លាស់ (៤) ត្រូវយកចិត្តទុកដាក់ធ្វើការវិភាគអំពីតម្លៃនិងនិន្នាការនៃទីផ្សារដែលភ្ជាប់ទៅនឹងប្រាក់ឈ្នួលពលកម្មនិង (៥) ត្រូវពិនិត្យឡើងវិញអំពីយន្តការគ្រប់គ្រងមួយឲ្យបានច្បាស់លាស់ ចំពោះចម្ការកៅស៊ូកសិ-ឧស្សាហកម្មនិងចម្ការកៅស៊ូគ្រួសាររួមទាំងរោងចក្រនិងសិប្បកម្មកែច្នៃជ័រនិងឈើកៅស៊ូបឋមផងដែរ

៣. ត្រូវសិក្សាបន្ថែម៖ (១) ការងារស្រាវជ្រាវបច្ចេកទេសដូចជា ការដាំដុះ ការថែទាំកូនកៅស៊ូ ការគ្រប់គ្រងសមាសភាពចង្រៃ សរីរសាស្ត្រ ទឹកជ័រ ការយកផល និងការកែច្នៃ ពិសេសការស្រាវជ្រាវរកពូជកៅស៊ូថ្មីៗដែលធន់នឹងការប្រែប្រួលអាកាស-ធាតុនិងមានទិន្នផលខ្ពស់ទាំងផលិតផលជ័រនិងឈើកៅស៊ូ (២) ពង្រីកទីតាំងស្ថានីយ៍និងមន្ទីរពិសោធន៍ និងបង្កើនសមត្ថភាពស្រាវជ្រាវផ្សព្វផ្សាយ និងផ្ទេរបច្ចេកវិទ្យា (៣) ត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការពង្រីក និងរក្សាទុកប្រភពផ្តល់រុក្ខសម្ភារកៅស៊ូសម្រាប់ការអភិវឌ្ឍន៍ចម្ការកៅស៊ូនាពេលអានាគត ជាពិសេសច្បារពូជដែលបានធ្វើ DNA រួចហើយ ព្រមទាំងសហការអនុវត្តនៅកម្មវិធីផ្លាស់ប្តូរក្លូនពហុភាគីក្នុងក្របខណ្ឌនៃប្រទេសជាសមាជិក IRRDB

៤.ត្រូវបន្តពង្រឹងសហគមន៍កសិកម្មកៅស៊ូគ្រួសារ ដើម្បីបង្កើតកាលានុវត្តភាពក្នុងការការពារផលប្រយោជន៍របស់កសិករទាំងការដាំដុះ ការយកផល ការកែច្នៃ ទាំងអំណាចចរចារថ្លៃ ពេលលក់ផលិតផលកៅស៊ូ និងការទិញធាតុចូល

៥.ត្រូវចូលរួមពង្រឹងសមត្ថភាពវិជ្ជាជីវៈរបស់មន្ត្រីគ្រប់លំដាប់ថ្នាក់ ជាពិសេស មន្ត្រីនៅតាមមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ដែលមានសក្តានុពលខាងកៅស៊ូ ដើម្បីមានសមត្ថភាពគ្រប់-គ្រាន់ក្នុងការចុះពង្រឹងសមត្ថភាពកសិករនិងសហគកៅស៊ូឲ្យមានបច្ចេកទេសជំនាញកាន់តែល្អប្រសើរ ដោយគិតគូរអំពីការបណ្តុះបណ្តាលនិងផ្សព្វផ្សាយបច្ចេកវិទ្យាដំណាំកៅស៊ូដល់កសិករបានច្រើនថែមទៀត រួមទាំងការធ្វើពិពិធកម្មដំណាំ ការថែទាំ ការដាំដំណាំចន្លោះរងកៅស៊ូដល់កសិករ ការយកផល ការទុកដាក់ផលិតផលជ័រកៅស៊ូ ការកែច្នៃកៅស៊ូ សន្លឹកព្រមទាំងបន្តបង្កើនការបណ្តុះបណ្តាលជំនាញចៀរជ័រដល់កសិករឲ្យបានច្រើ នស្របតាមសន្ទុះរីកចម្រើននៃផ្ទៃដីដែលត្រូវប្រមូលផល។ ជាពិសេសត្រូវយកចិត្តទុកដាក់ជួយណែនាំផ្សព្វផ្សាយបន្ថែមដល់កសិករដាំកៅស៊ូអំពីទីផ្សារកៅស៊ូតាមរយៈ ការបង្កើតប្រព័ន្ធផ្សព្វផ្សាយប្រកបដោយភាពវៃឆ្លាតនិងជៀសវាងការកាប់ដើមកៅស៊ូចោល នៅពេលដែលកៅស៊ូធ្លាក់ថ្លៃ

៦.ត្រូវបន្តកៀរគរនិងទាក់ទាញរកប្រភពហិរញ្ញប្បទាន ឬបច្ចេកវិទ្យាដៃគូអភិវឌ្ឍន៍ផ្សេងៗទៀត ជាពិសេសជាមួយទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) និងអង្គការស្បៀងអាហារនិងកសិកម្ម (FAO) ដើម្បីអនុវត្តការងារឲ្យសម្រេចគោលដៅសូចនាករនៃផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍនដំណាំកៅស៊ូកម្ពុជាឲ្យទទួលបានជោគជ័យ។ ត្រូវពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសផលិត និងប្រើប្រាស់កៅស៊ូសំខាន់ៗ តាមរយៈការរៀបចំចុះអនុស្សារណៈយោគយល់ (MOU) ដើម្បីផ្លាស់ប្តូរបច្ចេកវិទ្យា ការសិក្សាស្រាវជ្រាវ និងបទពិសោធន៍ល្អក៏ដូចជាការរកទីផ្សារថ្មីៗ។ ទន្ទឹមនឹងនេះ ក៏មិនត្រូវមើលរំលងអំពីការខិតខំអនុវត្តការប្រមូលចំណូលបានពីការជួលទីតាំងចម្ការកៅស៊ូនិងអចលនាទ្រព្យផ្សេងទៀតក្រោមសមត្ថកិច្ចរបស់ខ្លួនឲ្យបានសម្រេចតាមគោលដៅដែលបានគ្រោងទុកប្រកបទៅដោយតម្លាភាព

៧.ជួយសម្របសម្រួលនិងពង្រឹងសកម្មភាពរបស់សមាគមអភិវឌ្ឍន៍កៅស៊ូកម្ពុជា (ARDC) ដែលជាផ្នែកឯកជនដ៏សំខាន់ ដែលបានជួយទ្រទ្រង់ដល់ការអភិវឌ្ឍវិស័យកៅស៊ូឲ្យដំណើរការកាន់តែសកម្មទ្វេរឡើងនិងត្រូវប្រមូលផ្តុំគ្រប់ប្រតិបត្តិករកៅស៊ូទាំងអស់ឲ្យចូលជាសមាជិករបស់សមាគមនេះស្របតាមនីតិវិធី។ ទន្ទឹមនឹងនេះ ត្រូវបន្តកិច្ចសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជួយទប់ស្កាត់ការនាំចេញជ័រកៅស៊ូដោយខុសច្បាប់នៅតាមបណ្តាខេត្តជាប់ព្រំដែនប្រកបដោយប្រសិទ្ធភាពខ្ពស់។

ជាទីបញ្ចប់ ឯកឧត្តម **វេង សាខុន** បានថ្លែងអំណរគុណ និងសម្តែងនូវសេចក្តីសោមនស្សរីករាយកោតសរសើរ ព្រមទាំងបានវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ដែលបានចូលរួមចំណែកក្នុងបុព្វហេតុនៃការលើកកម្ពស់វិស័យកសិកម្មនៅកម្ពុជា ពិសេសអនុវិស័យកៅស៊ូធម្មជាតិនិងបានបំពាក់គ្រឿងឥស្សរិយយសជូនដល់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានកៅស៊ូចំនួន២៣នាក់ (ស្រី២នាក់) ដែលមានស្នាដៃល្អក្នុងការបម្រើការងារជូនជាតិមាតុភូមិនាពេលកន្លងមក។







## ២. សេចក្តីសន្និដ្ឋាន

ឆ្លងតាម កិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅអនុវត្តការងារឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានកៅស៊ូ អស់រយៈពេលមួយថ្ងៃកន្លះរួចមកយើងអាចធ្វើការវាយតម្លៃ និងសន្និដ្ឋាននូវចំណុចមួយចំនួនដូចតទៅ៖

- កិច្ចប្រជុំត្រូវបានបញ្ចប់ប្រកបដោយបរិយាកាសរីករាយស្និទ្ធស្នាលនិងមានសាមគ្គីភាពល្អរវាងថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ និងមន្ត្រីរាជការនៃអគ្គនាយកដ្ឋានកៅស៊ូក៏ដូចជា មន្ត្រីបម្រើការងារក្នុងការិយាល័យកៅស៊ូនៅតាមបណ្តាខេត្ត សមាគមកៅស៊ូ បណ្តាក្រុមហ៊ុនកៅស៊ូកសិឧស្សាហកម្ម ស្ថាប័នពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍
- ការអនុវត្តសកម្មភាពការងារចរន្តរបស់អគ្គនាយកដ្ឋានកៅស៊ូ និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូ

ក្នុងឆ្នាំ២០១៩ ទទួលបាននូវលទ្ធផលល្អប្រសើរ ដូចគោលដៅដែលបានគ្រោងទុក

- កិច្ចប្រជុំត្រូវបានបញ្ចប់ប្រកបដោយបរិយាកាសរីករាយស្និទ្ធស្នាលនិងមានសាមគ្គីភាពល្អ។

## ៣. ទិសដៅនិងវិធានការអនុវត្ត

សម្រាប់ឆ្នាំ២០២០ អគ្គនាយកដ្ឋានកៅស៊ូ បានដាក់ចេញនូវទិសដៅសំខាន់ៗ ដូចខាងក្រោម៖

- ជំរុញបង្កើនផ្ទៃដីចៀរជ័រឲ្យបាន៣០៦ ពាន់ហិកតា
- ជំរុញផលិតកម្មកៅស៊ូឲ្យបាន៣៥៣ ពាន់ហិកតា
- ជំរុញការនាំចេញកៅស៊ូឲ្យបាន៣៤៣ ពាន់ហិកតា
- រៀបចំបញ្ចប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍកៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០
- អនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធីឲ្យសម្រេចបាននូវចំណុចដៅដែលបានកំណត់។

វិធានការអនុវត្តនានា ដើម្បីសម្រេចទិសដៅដែលបានដាក់ចេញខាងលើ មានដូចខាងក្រោម៖

- បន្តយកចិត្តទុកដាក់ពិនិត្យ សិក្សាស្រាវជ្រាវ និងកសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា
- បន្តជំរុញកិច្ចសហការជាមួយអាជ្ញាធរដែនដី កងកម្លាំងមានសមត្ថកិច្ចតាមច្រកព្រំដែននិងអាជ្ញាធរពាក់ព័ន្ធក្នុងការទប់ស្កាត់ការនាំចេញជ័រនិងឈើកៅស៊ូមិនទាន់កែច្នៃទៅបរទេស
- ជំរុញក្រុមហ៊ុនឯកជនឲ្យអនុវត្តផែនការកម្មវិធីវិនិយោគកៅស៊ូលើសម្បទានដីសេដ្ឋកិច្ច និងវាយតម្លៃលទ្ធផលដែលសម្រេចបាន
- បន្តជំរុញបញ្ចប់ការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០
- បន្តអនុវត្តនិងពិនិត្យតាមដានការអនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធីឆ្នាំ២០២០ ឲ្យបានជោគជ័យតាមការគ្រោងទុក
- ខិតខំប្រមូលចំណូលឲ្យបានសម្រេចតាមគោលដៅ
- បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រស្តីពីការដាំដុះ ថែទាំកូនកៅស៊ូ ការគ្រប់គ្រងសមាសភាពចម្រៃ ការយកផល និងការកែច្នៃ
- បន្តសិក្សាដើម្បីសុំបង្កើតទីតាំងស្ថានីយនិងមន្ទីរពិសោធន៍បន្ថែម និងបង្កើនសមត្ថភាពស្រាវជ្រាវផ្សព្វផ្សាយនិងបង្ហាញ
- បន្តផ្សព្វផ្សាយនិងបណ្តុះបណ្តាលបច្ចេកវិទ្យាដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ
- ជំរុញការចងក្រងនិងពង្រឹងសហគមន៍កសិកម្មកៅស៊ូគ្រួសារ
- បន្តសហការនិងចូលរួមជាមួយដៃគូរអន្តរជាតិនិងអង្គការកៅស៊ូអន្តរជាតិនានាក្នុងក្របខណ្ឌការងារគ្រប់គ្រង ស្រាវជ្រាវ និងការអភិវឌ្ឍនបច្ចេកវិទ្យា
- ជំរុញស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារទាំងអស់ឲ្យមានលិខិតអនុញ្ញាតត្រឹមត្រូវ
- ពង្រីកនិងកៀរគររកដៃគូសហប្រតិបត្តិ

ការក្នុងការផ្ដល់ប្រភពថវិកា និងបច្ចេកទេស ដើម្បីគាំទ្រការអភិវឌ្ឍកៅស៊ូគ្រួសារ

- បន្តចូលរួមសហការជាមួយគ្រឹះស្ថានសិក្សានានាក្នុងការបណ្ដុះបណ្ដាលធនធានមនុស្សខាងអនុវិស័យកៅស៊ូ។

## ៤. សំណូមពរ

អគ្គនាយកដ្ឋានកៅស៊ូ ក៏បានសូមសំណូមពរដល់ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មេត្តាជួយគាំទ្រនិងមានវិធានការបន្ថែមរួមមាន៖

❖ សូមការគាំទ្រក្នុងការផ្ដល់និងបង្កើនថវិកាតាមកម្មវិធីបន្ថែមទៀត ដើម្បីជួយបង្កើនសកម្មភាពការងារចុះផ្សព្វផ្សាយនិងបណ្ដុះបណ្ដាលឲ្យបានកាន់តែច្រើនបន្ថែមទៀត

❖ សូមពិនិត្យលទ្ធភាពផ្ដល់មធ្យោបាយក្នុងការបំពេញការងារ (រថយន្ត) ក្នុងការចុះបំពេញបេសកកម្មតាមបណ្ដាខេត្ត

❖ សូមបំពេញបន្ថែមចំនួនមន្ត្រីថ្មីយ៉ាងហោចណាស់ឲ្យសមាមាត្រទៅនឹងចំនួនមន្ត្រីដែលបានចូលនិវត្តន៍

❖ សូមជំរុញនិងណែនាំឲ្យបណ្ដាក្រុមហ៊ុនចម្ការកៅស៊ូកសិ-ឧស្សាហកម្មទាំងអស់ត្រូវផ្ដល់នូវរបាយការណ៍សកម្មភាពរបស់ខ្លួនប្រចាំខែ ប្រចាំឆ្នាំមកអគ្គនាយកដ្ឋានកៅស៊ូ ឲ្យបានទាន់ពេលវេលាតាមការកំណត់

❖ សូមផ្ដល់ទីតាំង និងផ្ទៃដីសម្រាប់សាងសង់អនុស្ថានីយពិសោធន៍និងស្រាវជ្រាវដំណាំកៅស៊ូនៅតាមតំបន់មានសក្ដានុពលសម្រាប់ដំណាំកៅស៊ូ៕

## វគ្គបណ្ដុះបណ្ដាលច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ នៅខេត្តកំពង់ចាម

ចាប់ពីថ្ងៃទី១០-១៧ ខែកុម្ភៈ ឆ្នាំ២០២០ ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃនាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ បានចុះបំពេញបេសកកម្មនៅខេត្តកំពង់ចាម ដើម្បីបើកវគ្គបណ្ដុះបណ្ដាលច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារក្នុងគោលបំណង៖ ដើម្បីឲ្យកសិករយល់ដឹងពីសារៈប្រយោជន៍នៃដំណាំកៅ-ស៊ូដូចជាការដាំដុះ ការថែទាំ ការបង្ការ និងការព្យា-បាលជំងឺ ការបើកមុខចៀរជ័រដំបូង និងបទដ្ឋានបច្ចេកទេសចៀរជ័រ ជាពិសេស ការយកផលទទួលបានទិន្នផលខ្ពស់និងត្រឹមត្រូវតាមបទដ្ឋាន។

វគ្គបណ្ដុះបណ្ដាលនេះ បានរៀបចំនៅសាលប្រជុំឃុំអូរម្លូដោយមានការអញ្ជើញចូលរួមជាគណៈអធិបតី លោក **ហ៊ឹម អួន** អគ្គនាយករង នៃអគ្គ-នាយកដ្ឋានកៅស៊ូ លោក **ម៉ី សុផារ៉ា** តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាម និងលោក **យឿង ស៊ា** ជំទប់ទី២ ឃុំអូរម្លូ ស្រុកស្ទឹងត្រង់។ វគ្គបណ្ដុះបណ្ដាលនេះ មានកសិករកៅស៊ូគ្រួសារសរុប៦០នាក់ (ស្រី១៥នាក់) ។



*គណៈអធិបតីក្នុងពិធីបើកវគ្គបណ្តុះបណ្តាល*

ជាកិច្ចចាប់ផ្តើម លោក **យឿង ស៊ា** បានមានមតិស្វាគមន៍និងសម្តែងនូវក្តីរីករាយដែលក្រុមការងារនៃអគ្គនាយកដ្ឋានកៅស៊ូបានធ្វើការបណ្តុះបណ្តាលច្ចេកទេសដំណាំកៅស៊ូនៅមូលដ្ឋានឃុំ អូរម្លូ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម និងបានជម្រាបជូនអំពីស្ថានភាពទូទៅ ជាពិសេស ស្ថានភាពអនុវិស័យកៅស៊ូនៅក្នុងឃុំជូនដល់អង្គពិធីឱ្យបានជ្រាប។

បន្ទាប់មក លោក **ម៉ី សុធារ៉ា** បានសម្តែងចំណាប់អារម្មណ៍ចំពោះវគ្គបណ្តុះបណ្តាលនេះ ថាពិតជាបានផ្តល់នូវសារៈសំខាន់ ដល់កសិករកៅស៊ូគ្រួសារក្នុងការយល់ដឹងអំពីច្ចេកទេសដំណាំកៅស៊ូដើម្បីថែរក្សាចម្ការកៅស៊ូរបស់ខ្លួន។ លោកក៏បានជម្រាបអំពីស្ថានភាពទូទៅនៃវិស័យកសិកម្មនៅក្នុងខេត្តទាំងមូលនិងដោយឡែកសម្រាប់ស្រុកស្ទឹងត្រង់នេះ ព្រមទាំងស្នើឲ្យបងប្អូនកសិករខិតខំយកចិត្តទុកដាក់ថែទាំចម្ការកៅស៊ូដែលបានចៀរជ័រហើយព្រោះដំណាំនេះផ្តល់ផលរយៈពេលវែង ដែលអាចជួយដល់សេដ្ឋកិច្ចបានច្រើន។

ជាកិច្ចបន្តលោក **ហ៊ឹម អូន** បានសម្តែងនូវក្តីរីករាយ ចំពោះវត្តមានបងប្អូនកសិករដែលបានអញ្ជើញចូលរួមវគ្គបណ្តុះបណ្តាលនាពេលនេះ ព្រមទាំងមានមតិសំណេះសំណាល ដោយគូសបញ្ជាក់ថាវគ្គបណ្តុះបណ្តាលនេះ ពិតជាមានសារៈសំខាន់សម្រាប់កសិករកៅស៊ូគ្រួសារ ពិសេសកសិករដែលគ្រោងនឹងដាំដុះកៅស៊ូ និងកសិករដែលនឹងត្រៀមរៀបចំបើកមុខចៀរដំបូងដែលត្រូវយកចិត្តទុកដាក់បំផុតលើបទដ្ឋានបច្ចេកទេសចៀរជ័រឱ្យបានត្រឹមត្រូវតាមការណែនាំរបស់អ្នកបច្ចេកទេស។ លោកបានជម្រាបជូនពីសារៈប្រយោជន៍របស់ដំណាំកៅស៊ូរួមមាន៖ ផ្តល់ប្រាក់ចំណូលដល់សេដ្ឋកិច្ចគ្រួសារ និងជាតិ បង្កើតការងារ និងមុខរបរមានស្ថេរភាពជូនប្រជាពលរដ្ឋ ការពារការហូរច្រោះដី និងការបង្កើតជាគម្របបៃតងឡើងវិញដើម្បីជួយកាត់បន្ថយ ការប្រែប្រួលអាកាសធាតុ និងផ្តល់ជាឈើសម្រាប់ប្រើប្រាស់ជាគ្រឿងសំណង់ សង្ហារឹម ឈើឥន្ធនៈ និងចុងក្រោយបានប្រកាសឱ្យបើកវគ្គបណ្តុះបណ្តាល។



*រូបថតជាអនុស្សាវរីយ៍*

បន្ទាប់ពី បានសម្រាកពិសារអាហារសម្រន់រួចមក ក្រុមការងារបានធ្វើការបណ្តុះបណ្តាលតាមកម្មវិធីដែលបានគ្រោងទុកដែលក្នុងនោះបទបង្ហាញលើផ្នែកទ្រឹស្តីត្រូវបានធ្វើឡើង ដោយមានការចោទ

ជាសំនួរជាច្រើនពីកសិករគឺទាក់ទងទៅនឹងការងារបច្ចេកទេសដំណាំកៅស៊ូផងដែរ។

វគ្គបណ្តុះបណ្តាលនេះ ក្រុមការងារនិងគ្រូបង្គោលបានធ្វើបទបង្ហាញលើផ្នែកទ្រឹស្តី និងអនុវត្តចៀរដោយផ្ទាល់នៅនឹងកន្លែងចំនួនប្រាំថ្ងៃតាមផ្នែកនីមួយៗដូចខាងក្រោម៖

**ក. ផ្នែកទ្រឹស្តី**

១. ស្ថានភាពដំណាំកៅស៊ូនៅកម្ពុជា

២. ការដាំដុះនិងការថែទាំ

៣. ដំណាំចន្លោះរង

៤. ការបង្ការនិងការព្យាបាលជំងឺ

៥.ការបើកមុខចៀរជ័រដំបូងនិងបទដ្ឋានបច្ចេកទេសចៀរជ័ររួមមាន៖

- ✓ លក្ខខណ្ឌចាំបាច់សម្រាប់ការបើកមុខចៀរដំបូង
- ✓ បទដ្ឋានបច្ចេកទេសក្នុងការចៀរជ័រ
- ✓ ការគ្រប់គ្រងផ្ទាំងមុខចៀរ
- ✓ ការប្រើប្រាស់ថ្នាំរំញោច។



*មន្ត្រីបច្ចេកទេសពន្យល់ពីបច្ចេកទេសកៅស៊ូ*

**ខ. ផ្នែកអនុវត្ត**

១.វាស់ទំហំដើមដែលត្រូវបើកមុខចៀរដំបូង និងវិធីកំណត់ចំណាំដើមដែលមានទំហំមិនទាន់គ្រប់ខ្នាតនិងគ្រប់ខ្នាត (ទំហំគ្រប់ខ្នាត៥០ស.មដោយវាស់នៅកម្ពស់១ម ពីដី)

២.របៀបបែងចែកដើមជាពីរដើម្បីបើកមុខចៀរដំបូង

៣.ក្រិតកំពស់មុខចៀរ ស្លាបព្រា កងទ្រចាន របៀបបញ្ចុះស្លាបព្រា និងចងកងចាន

៤.គូសក្រិតផ្ទាំងចៀរសម្រាប់រយៈពេលមួយឆ្នាំ ដោយប្រើទង់ជ័យដែលមានមុំ៣០ដឺក្រេ

៥.របៀបកាន់ពន្លាក ចលនាបំលាស់ទីក្នុងពេលចៀរនិងរបៀបបើកមុខចៀរចំនួន៣ពន្លាកដំបូង

៦.ការចំណាយសំបកក្នុងមួយពន្លាក ជម្រៅនិងចំណោតមុខចៀរ

៧.ការថែទាំមុខចៀរក្នុងអំឡុងពេលចៀរ និងពេលដើមកៅស៊ូសម្រាកចៀរ(កៅស៊ូជ្រុះស្លឹក)។ បន្ទាប់មកកសិករម្នាក់ៗ បានរៀនចៀរជ័រលើដើមកៅស៊ូរបស់ខ្លួននិងការចៀរបំលាស់ទីពីដើមមួយទៅដើមមួយរយៈពេលប្រាំថ្ងៃ ដោយមានការណែនាំបន្ថែមពីគ្រូបង្គោល។





*មន្ត្រីបច្ចេកទេសពន្យល់ពីបច្ចេកទេសកៅស៊ូ*

តាមរយៈ វគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារនៅក្នុងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម បានបង្ហាញឲ្យឃើញថា៖

១.កសិករបានចូលរួមយ៉ាងផុសផុលនិងបានយកចិត្តទុកដាក់ខ្ពស់ ចំពោះវគ្គបណ្តុះបណ្តាលទាំងផ្នែកទ្រឹស្តីនិងការអនុវត្តផ្ទាល់

២.កសិករភាគច្រើនមានការយល់ដឹងបានកាន់តែច្បាស់អំពីបច្ចេកទេសដំណាំកៅស៊ូ ពិសេសបច្ចេកទេសចៀរជ័រដូចជា ការកំណត់ទំហំដើមកៅស៊ូចំនួនដើមដែលត្រូវបើកមុខចៀរដំបូង ការកំណត់កំពស់មុខចៀរ ស្លាបព្រា កងទ្រចាន ការកំណត់ផ្ទាំងចៀរ រយៈពេលចៀរក្នុងមួយឆ្នាំ របៀបកាន់ពន្លាកចៀរ ចលនាបំលាស់ទីរបស់ជើងក្នុងពេលចៀរ ការចំណាយសំបក ការថែទាំផ្ទាំងមុខចៀរ និងការគ្រប់គ្រងផ្ទាំងមុខចៀរ។ ទន្ទឹមនឹងនេះ កសិករយល់ដឹងអំពីពេលវេលាដែលត្រូវចៀរ និងរបៀបសារជ័រតាមនៅដើមនីមួយៗ ដើម្បីប្រមូលទឹកជ័រឲ្យបានកម្រិតអតិបរិមា។

៣.តំណាងកសិករដែលចូលរួមបានថ្លែងអំណរគុណដល់អគ្គនាយកដ្ឋានកៅស៊ូ ដែលបានចាត់មន្ត្រីជំនាញក្នុងការបើកវគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារនៅឃុំអូរម្លូ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម និងសំណូមពរសុំឲ្យក្រុមការងារបន្តចុះបើកវគ្គបណ្តុះបណ្តាលនេះឲ្យបានរាល់ឆ្នាំ ព្រមទាំងជួយចុះផ្សព្វ-ផ្សាយថ្លៃកៅស៊ូជូនពួកគាត់ដែលជាម្ចាស់ចម្ការផង៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកៅស៊ូ

## របាយការណ៍សរុប
## ស្តីពី
## ស្ថានភាពការងាររបស់អគ្គនាយកដ្ឋានកៅស៊ូ ប្រចាំខែកុម្ភៈ ឆ្នាំ២០២០
## និងទិសដៅអនុវត្តបន្ត

### ១.សេចក្តីផ្តើម

ក្នុងឆ្នាំ២០២០នេះអគ្គនាយកដ្ឋានកៅស៊ូ បានអនុវត្តការងារចម្បងៗ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ទាំងការងារចរន្ត ការងារអនុវត្តគម្រោងថវិកាតាមកម្មវិធី ការងារដាំដុះ ថែទាំកូនកៅស៊ូថ្មី ការងារអាជីវកម្ម ផលិតកម្ម និងធុរកិច្ចទាំងកៅស៊ូគ្រួសារនិងកៅស៊ូកសិឧស្សាហកម្ម និងការងារផ្សេងៗទៀតបានដំណើរការជាធម្មតា។ ជាលទ្ធផលការងារសំខាន់ៗ ដែលអគ្គនាយកដ្ឋានកៅស៊ូសម្រេចបានក្នុងខែកុម្ភៈ ឆ្នាំ២០២០ មានខ្លឹមសារលម្អិតជូនដូចខាងក្រោម៖

### ២.លទ្ធផលការងារសម្រេចបាន

#### ២.១ ការងារអាជីវកម្ម ផលិតកម្ម និងធុរកិច្ចកៅស៊ូ

##### ២.១.១ ផ្ទៃដីកៅស៊ូ

ផ្ទៃដីកៅស៊ូសរុបមានចំនួន ៤០៥ ៤៨៥ ហិកតា ដែលក្នុងនោះ៖ ផ្ទៃដីចៀរជ័រមានចំនួន ២៥០ ៧៥០ហិកតា ស្មើនឹង៦២% និងផ្ទៃដីថែទាំមានចំនួន១៥៤ ៧៣៥ហិកតា ស្មើនឹង៣៨%។

##### ២.១.២ ផលិតកម្ម

- ផលិតផលជ័រកៅស៊ូសម្រេចបានប្រចាំខែកុម្ភៈ ឆ្នាំ២០២០ មានចំនួន១៣ ២៤៦តោន បានថយចុះចំនួន ១៥ ៩៥៧ តោនស្មើនឹង៥៥%ធៀបនឹងខែមុននិងបានថយចុះចំនួន១០ ៩៥៨ស្មើនឹង៤៤%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។

- ផលិតផលជ័រកៅស៊ូសរុបគិតមកដល់ខែកុម្ភៈ ឆ្នាំ២០២០ សម្រេចបានចំនួន ៤២ ៤៤៩តោន បានថយចុះចំនួន ៥ ៦៤៦តោន ស្មើនឹង១២% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

##### ២.១.៣ ធុរកិច្ចកៅស៊ូ

- បរិមាណបញ្ចេញលក់ជ័រកៅស៊ូសម្រេចបានក្នុងខែកុម្ភៈ ឆ្នាំ២០២០ មានចំនួន១៣ ៨៦២តោន ថយចុះចំនួន ១៣ ៥៨៣តោន ស្មើនឹង៤៩%ធៀបនឹងខែមុននឹងបានកើនឡើងចំនួន ៨១៨ស្មើនឹង៦%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។

- បរិមាណបញ្ចេញលក់សរុបគិតមកដល់ខែកុម្ភៈ ឆ្នាំ២០២០ សម្រេចបានចំនួន ៤១ ៣០៦តោន កើនឡើងចំនួន៤ ៨១២តោន ស្មើនឹង១៣%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

- តម្លៃលក់មធ្យមក្នុងខែកុម្ភៈ ឆ្នាំ២០២០ មានចំនួន ១ ៤១៤ដុល្លារ/តោន បានថយចុះចំនួន១៩ដុល្លារ/តោន ស្មើនឹង១,៣៣%ធៀបនឹងខែមុន និងបានកើនឡើងចំនួន១១៤ដុល្លារ/តោនស្មើនឹង៩%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។

- តម្លៃលក់កៅស៊ូជាមធ្យមគិតមកដល់ខែកុម្ភៈ ឆ្នាំ២០២០ គឺ១ ៤២៦ ដុល្លារ/តោន បានកើនឡើងចំនួន ១៧៤ ដុល្លារ/តោន ស្មើនឹង១៤% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។


អាស័យដ្ឋាន: ផ្លូវជាតិលេខ៦អា ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កម្ពុជា
Address: National Road No.6A, Phum Bakkheng, Sangkat Prek Leap, Khan Chroy Changva, Phnom Penh
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៦៧២២ ៥៩០
Phone: (855) 23 6722 590, Email:gdr.maff@gmail.com

- ក្នុងខែកុម្ភៈ តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅមាត់ចម្ការ គឺទឹកជ័រ (DRC 100%) ថ្លៃ៤ ៦០០-៤ ៨២៥៛/គ.ក្រ (ពុំមានការកើនឡើងទេ ធៀបនឹងខែមុន) និងជ័រកក (DRC 50%) ថ្លៃ២ ០៧៥-២ ៥៦៣៛/គ.ក្រ (ថយចុះចំនួន៩១៛/គ.ក្រ ធៀបនឹងខែមុន) អាស្រ័យតាមតំបន់។

## ២.២. ការងារចរន្តនិងការអនុវត្តគម្រោងសកម្មភាពថវិកាតាមកម្មវិធី

### ២.២.១. ការងារចរន្ត

- ប្រជុំរៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត
- ចុះផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត ពាក់ពន្ធ័វិស័យកៅស៊ូ នៅស្រុកអូរយ៉ាដា ខេត្តរតនគីរី
- បានចុះពិនិត្យ តាមដាន និងវាយតម្លៃវឌ្ឍនភាពរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចសម្រាប់ឆ្នាំ ២០១៩ ជាមួយក្រុមការងារ(ELC)របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានខេត្ត ក្រចេះ មណ្ឌលគីរី ត្បូងឃ្មុំ ស្ទឹងត្រែង ស្វាយរៀង កំពង់ចាម ព្រះវិហារ កំពត កោះកុង និងខេត្តព្រះសីហនុ
- បានចុះបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូ ដល់កសិករកៅស៊ូគ្រួសារ ខេត្តកំពង់ចាម
- បានចុះបើកវគ្គពង្រឹងសហគមន៍កសិកម្មកៅស៊ូគ្រួសារ នៅស្រុកសំឡូត ខេត្តបាត់ដំបង
- បានចុះបើកវគ្គពង្រឹងសហគមន៍កសិកម្មកៅស៊ូគ្រួសារ នៅខេត្តមណ្ឌលគីរី
- រៀបចំគម្រោងផែនការសកម្មភាពថវិកាកម្មវិធីឆ្នាំ២០២១
- រៀបចំប្រជុំពិនិត្យនិងពិភាក្សាបន្តលើការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅ ឆ្នាំ២០៣០
- ផ្សព្វផ្សាយពត៌មានអំពីថ្លៃកៅស៊ូនៅទីផ្សារក្នុងនិងក្រៅប្រទេសតាមវិទ្យុ ដើម្បីជំរុញថ្លៃលក់ជ័រកៅស៊ូ អោយបានប្រសើរ
- ប្រជុំពិនិត្យនិងសម្រេចព្រឹត្តិបត្រកៅស៊ូធម្មជាតិប្រចាំខែកុម្ភៈ ឆ្នាំ២០២០
- បានប្រមូលទិន្នន័យ និងរៀបចំតម្លៃកៅស៊ូធម្មជាតិសម្រាប់ផ្សាយប្រចាំសប្តាហ៍តាមវិទ្យុមណ្ឌលព័ត៌មាន ស្ត្រីកម្ពុជា(FM103.5)ចំនួន០៤ដងក្នុងមួយខែ(១សប្តាហ៍១ដង) និងបានផ្សាយបន្តផ្ទាល់ទៅតាម បណ្តាលខេត្តចំនួន៤ខេត្ត គឺខេត្តបាត់ដំបង(FM106.3) ខេត្តកំពង់ចាម(FM99.3) ខេត្តកំពង់ធំ (FM104) និង ខេត្តសៀមរាប(FM107) រៀងរាល់ថ្ងៃចន្ទ វេលាម៉ោង១០ព្រឹក
- អនុវត្តន៍ភារកិច្ចផ្សេងៗទៀត។

### ២.២.២. ការចំណាយថវិកាតាមគម្រោងកម្មវិធី

ការចំណាយថវិកាក្នុងខែកុម្ភៈ ឆ្នាំ២០២០ មានចំនួន ១១៦ ៧៦០ ០០០រៀល។ បើគិតរហូតមកដល់ខែកុម្ភៈនេះ មានចំនួន២១៩ ៩៧០ ០០០រៀល ស្មើនឹង១៧,៣៣ ភាគរយនៃផែនការ។

### ២.២.៣. ការប្រមូលចំណូលថវិកា

ការប្រមូលចំណូលថ្លៃឈ្នួលដីវិនិយោគចម្ការកៅស៊ូរដ្ឋទាំង៧ ចម្ការកៅស៊ូរដ្ឋឡាបានសៀកខេត្តរតនគីរី និង ក្រុមហ៊ុនទីហរ័ណ អាហរ័ណកៅស៊ូ ក្នុងខែកុម្ភៈ ឆ្នាំ២០២០ បានចំនួន៣៩៥ ៥១៨ ៩៦០រៀល ស្មើនឹង២៧,១៩ ភាគរយនៃផែនការ។

## ៣. ទិសដៅបន្ត

- បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធកៅស៊ូ
- បន្តចុះបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូ ដល់កសិករកៅស៊ូគ្រួសារ
- បន្តចុះពង្រឹង និងចងក្រងសហគមន៍កសិកម្មកៅស៊ូគ្រួសារ

២/២

- បន្តចុះពិនិត្យ និងវាយតម្លៃបច្ចេកទេសដំណាំកៅស៊ូរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច
- បន្តអនុវត្តគម្រោងផែនការសកម្មភាពថវិកាកម្មវិធីសម្រាប់ឆ្នាំ២០២០
- រៀបចំគម្រោងផែនការសកម្មភាពថវិកាកម្មវិធីឆ្នាំ២០២១
- បន្តខិតខំធ្វើទំនាក់ទំនងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ ទីភ្នាក់ងារកៅស៊ូ និងអង្គការកៅស៊ូអន្តរជាតិនានាក្នុងក្របខណ្ឌការងារស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យា វិទ្យាសាស្ត្រ
- បន្តចុះពង្រឹង និងចងក្រងសហគមន៍ កសិករកៅស៊ូគ្រួសារសម្រាប់រៀបចំព្រឹត្តិបត្រប្រចាំខែ និងផ្សព្វផ្សាយតម្លៃកៅស៊ូធម្មជាតិតាមវិទ្យុប្រចាំសប្តាហ៍ និងលើគេហទំព័រហ្វេសប៊ុក របស់អគ្គនាយកដ្ឋានកៅស៊ូ
- បន្តអនុវត្តភារកិច្ចផ្សេងៗទៀត។

**បានឃើញនិងឯកភាព**
**ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**
**អគ្គនាយករង**

**ចាន់_វឌ្ឍនា**

ថ្ងៃព្រហស្បតិ៍ ៤រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០២០
**ប្រធាននាយកដ្ឋានរដ្ឋបាលនិងនីតិកម្ម**

**ឃួន_ផល្លា**

៣/២

# ស្ថានភាពផលិតកម្មកៅស៊ូប្រចាំខែកុម្ភៈ ឆ្នាំ២០២០

| លរ | ចម្ការកៅស៊ូ | ផ្ទៃដី(ហិកតា) | | | ឆ្នាំ២០១៩ | | | | សន្និធិដើមឆ្នាំ | ឆ្នាំ២០២០ | | | | ប្រៀបធៀប | | | | | | | | | | | | | | សន្និធិ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ផលិតផល(តោន) | | បញ្ចេញលក់(តោន) | | | ផលិតផល(តោន) | | បញ្ចេញលក់(តោន) | | ខែមុន | | | | | | រយៈពេលដូចគ្នាឆ្នាំមុន | | | | | | | | |
| | | ចៀរជ័រ | ថែទាំ | សរុប | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ផ្ទៃដីសរុប | | ផលិតផល | | បញ្ចេញលក់ | | ផលិតផល | | | | បញ្ចេញលក់ | | | | |
| | | | | | | | | | | | | | | | | | | | | ខែនេះ | | ដល់ខែនេះ | | ខែនេះ | | ដល់ខែនេះ | | |
| | | | | | | | | | | | | | | ហិកតា | % | តោន | % | តោន | % | តោន | % | តោន | % | តោន | % | តោន | % | |
| | I. កៅស៊ូកសិឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | |
| ក | ចម្ការកៅស៊ូកសិឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | |
| 1 | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | 670 | 132 | 801 | 25 | 82 | - | - | 158 | 13 | 48 | 15 | 15 | 0 | 0 | -22 | -63 | 15 | 100 | -12 | -48 | -34 | -42 | 15 | 100 | 15 | 100 | 191 |
| 2 | ក្រុមហ៊ុនសុភក្តិនីកា អ៊ិនវេសមេន គ្រុប | 11.971 | 3.262 | 15.233 | 706 | 2.297 | 1.219 | 3.147 | 1.093 | 704 | 2.299 | 390 | 1.326 | 0 | 0 | -891 | -56 | -547 | -58 | -2 | 0 | 2 | 0 | -830 | -68 | -1.820 | -58 | 2.065 |
| 3 | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | 1.118 | 1.247 | 2.365 | 96 | 276 | 210 | 336 | 21 | 62 | 220 | 210 | 210 | 0 | 0 | -95 | -60 | 210 | 100 | -34 | -35 | -56 | -20 | 0 | 0 | -126 | -38 | 31 |
| 4 | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខូអិលធីឌី | 6.103 | 1.912 | 8.015 | 237 | 715 | 396 | 878 | 618 | 214 | 648 | 515 | 797 | -463 | -5 | -220 | -51 | 232 | 82 | -23 | -10 | -67 | -9 | 118 | 30 | -81 | -9 | 469 |
| 5 | ក្រុមហ៊ុនស៊ីហ្វ វ៉ាប់ប៊ើ លីមីតធីត(រតនគិរី) | 306 | 2.418 | 2.724 | - | 7 | - | - | 365 | 15 | 47 | - | - | 0 | 0 | -17 | -53 | 0 | 0 | 15 | 100 | 41 | 608 | 0 | 0 | 0 | 0 | 412 |
| 6 | ក្រុមហ៊ុនស៊ីហ្វ រីសសស់ លីមីធីត(ស្នួល) | 4.174 | 76 | 4.250 | - | 561 | 168 | 714 | 1.911 | - | 376 | 513 | 945 | -156 | -4 | -376 | 0 | 81 | 19 | 0 | 0 | -185 | -33 | 345 | 205 | 231 | 32 | 1.342 |
| 7 | ក្រុមហ៊ុនឡុងស្រេងអ៊ិនធើណេស៊ិនណល | 3.908 | 278 | 4.186 | 161 | 567 | 210 | 210 | 706 | 34 | 414 | 400 | 925 | 0 | 0 | -347 | -91 | -125 | -24 | -127 | -79 | -153 | -27 | 190 | 90 | 715 | 340 | 195 |
| 8 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ចម្ការអណ្តូង) | 3.312 | 1.570 | 4.882 | 64 | 191 | | 250 | 613 | 27 | 137 | - | 230 | 188 | 4 | -83 | -76 | -230 | 0 | -37 | -58 | -54 | -28 | 0 | 0 | -20 | -8 | 520 |
| 9 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ពាមជាំង+រមាសហែក) | 1.918 | 1.119 | 3.037 | 23 | 107 | | 100 | 380 | 32 | 115 | - | 129 | 0 | 0 | -51 | -62 | -129 | 0 | 9 | 41 | 8 | 8 | 0 | 0 | 29 | 29 | 367 |
| 10 | ក្រុមហ៊ុនក្រេក(ខេមបូឌា) ខូអិលធីឌី | 4.639 | 159 | 4.798 | 478 | 1.177 | 840 | 1.260 | 550 | 346 | 945 | 420 | 630 | 0 | 0 | -254 | -42 | 210 | 100 | -132 | -28 | -232 | -20 | -420 | -50 | -630 | -50 | 865 |
| | សរុប ក | 38.120 | 12.173 | 50.293 | 1.789 | 5.979 | 3.044 | 6.895 | 6.415 | 1.446 | 5.249 | 2.462 | 5.206 | -431 | -1 | -2.357 | -62 | -283 | -10 | -343 | -19 | -731 | -12 | -582 | -19 | -1.688 | -24 | 6.457 |
| ខ | ចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ច | 79.361 | 114.727 | 194.088 | 4.200 | 12.400 | 4.000 | 11.800 | 3.653 | 5.000 | 15.600 | 4.800 | 15.000 | 0 | 0 | -5.600 | -53 | -5.400 | -53 | 800 | 19 | 3.200 | 26 | 800 | 20 | 3.200 | 27 | 4.253 |
| | សរុបI=ក+ខ | 117.481 | 126.901 | 244.382 | 5.989 | 18.379 | 7.044 | 18.695 | 10.068 | 6.446 | 20.849 | 7.262 | 20.206 | -431 | 0 | -7.957 | -55 | -5.683 | -44 | 457 | 8 | 2.469 | 13 | 218 | 3 | 1.512 | 8 | 10.710 |
| | II. កៅស៊ូគ្រួសារ | 133.269 | 27.834 | 161.103 | 17.715 | 29.715 | 6.000 | 17.800 | 7.076 | 6.800 | 21.600 | 6.600 | 21.100 | 0 | 0 | -8.000 | -54 | -7.900 | -54 | -10915 | -62 | -8.115 | -27 | 600 | 10 | 3.300 | 19 | 7.576 |
| | សរុបរួមI+II | 250.750 | 154.735 | 405.485 | 23.704 | 48.094 | 13.044 | 36.495 | 17.144 | 13.246 | 42.449 | 13.862 | 41.306 | -431 | -0,106 | -15.957 | -55 | -13.583 | -49 | -10458 | -44 | -5.646 | -12 | 818 | 6 | 4.812 | 13 | 18.286 |

បញ្ជាក់៖

(១) ផ្ទៃដីសរុបមានចំនួន ៤០៥ ៤៨៥ ហត ( ផ្ទៃដីចៀរជ័រ ២៥០ ៧៥០ ហត ថែទាំ ១៥៤ ៧៣៥ហត) បានថយចុះ៤៣១ហត ស្មើនិង០,១០៦% ។

(២) ផលិតផលសរុបចំនួន ១៣ ២៤៦ តោន បានថយចុះចំនួន ១៥ ៩៥៧ តោន (៥៥%) ធៀបនិងខែមុន និងបានថយចុះចំនួន១០ ៤៥៨តោន ស្មើនិង(៤៤%) ធៀបនិងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

(៣) រហូតមកដល់ខែកុម្ភៈ ឆ្នាំ២០២០ ផលិតផលសរុប ៤២ ៤៤៩ តោន បានថយចុះចំនួន ៥ ៦៤៦តោន ( ១២%)ធៀបនិងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

(៤) ការបញ្ចេញលក់សរុបចំនួន ១៣ ៨៦២តោន បានថយចុះចំនួន ១៣ ៥៨៣ តោន (៤៩%)ធៀបនិងខែមុន និងបានកើនឡើងចំនួន ៨១៨ ស្មើនិង(៦%)រយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

(៥) រហូតមកដល់ខែកុម្ភៈ ឆ្នាំ២០១៩ ការបញ្ចេញលក់សរុបចំនួន ៤១ ៣០៦តោន បានកើនឡើងចំនួន៤ ៨១២ តោន (១៣%) ធៀបនិងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

(៦)សន្និធិចុងគ្រាមានចំនួន១៨ ២៨៦ តោន

បានឃើញ និងឯកភាព
ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ
អគ្គនាយករង
ចាន់_វឌ្ឍនា

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋានរដ្ឋបាល និងនីតិកម្ម
ឃួន_ឥណ្ឌា

ថ្ងៃព្រហស្បតិ៍ ៤រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែមីនា ឆ្នាំ២០២០
អ្នកធ្វើតារាង
ធូ ស៊ិនឌី

# ព័ត៌មានអន្តរជាតិ

## របាយការណ៍ទីក្រុងកៅស៊ូឆ្លាត

*ឯកសារយោង៖ Rubber Market Intelligence report*

*ប្រែសម្រួលដោយកញ្ញា* ***ទូ ស្រីស***

**កត្តានានាបានជះឥទ្ធិពលដល់ថ្លៃកៅស៊ូធម្មជាតិនៅសប្តាហ៍ទី២ នៃខែកុម្ភៈ**

លទ្ធផលនៃការរំពឹងទុកនិងរបាយការណ៍ដែលបានចេញផ្សាយក៏បានបង្ហាញដូចគ្នាថា ថ្លៃកៅស៊ូធម្មជាតិមិនបានធ្លាក់ចុះខ្លាំងទេ ហើយក៏បានងើបឡើងវិញបន្តិចម្តងៗនៅពាក់កណ្តាលសប្តាហ៍ទី១ នៃខែកុម្ភៈ។ ការងើបឡើងវិញនេះមានភាពយឺតនិងស្ទើរបន្តិច បើធៀបទៅនឹងការរំពឹងទុក កាលចេញផ្សាយលើកមុន។

នៅតាមបណ្តាទីផ្សារសំខាន់ៗបានធ្លាក់ចុះប្រហែល១៦% ក្នុងសប្តាហ៍ទី២នៃខែមករាបន្ទាប់ពីមានការផ្ទុះឡើងភ្លាមៗនៃវីរុសកូរ៉ូណាផ្ទុយទៅវិញ ក៏មានការឡើងវិញននៅក្នុងសប្តាហ៍ទី១ នៃខែកុម្ភៈ ប្រមាណតែ៦%ប៉ុណ្ណោះ។ គម្លាតធ្លាក់ចុះថ្លៃកៅស៊ូទឹកជ័រខុសគ្នាច្រើនបើធៀបនឹងផលិតផលជ័រកៅស៊ូផ្សេងៗទៀត នៅពាក់កណ្តាលខែមករា ថ្លៃកៅស៊ូទឹកជ័រធ្លាក់ត្រឹមតែ១០%ប៉ុណ្ណោះ និងផលិតផលជ័រកៅស៊ូផ្សេងៗទៀតធ្លាក់ចុះ១៦%ឯនោះ ប៉ុន្តែ នៅពាក់កណ្តាលខែកុម្ភៈថ្លៃកៅស៊ូទឹកជ័របានកើនឡើង ៨%វិញ។

ខាងក្រោមនេះ គឺជាកត្តាគន្លឹះដែលមានឥទ្ធិពលលើថ្លៃកៅស៊ូក្នុងសប្តាហ៍ទី១ នៃខែកុម្ភៈ៖

១.រំញោចទីផ្សារបានរងផលប៉ះពាល់យ៉ាងខ្លាំងពីការផ្ទុះឡើងនៃវីរុសកូរ៉ូណា ដែលជះឥទ្ធិពលទៅលើសេដ្ឋកិច្ចពិភពលោក ជាពិសេសបណ្តាប្រទេសនៅអាស៊ី និងពិសេសទៅទៀតគឺប្រទេសចិនដែលត្រូវការកៅស៊ូធម្មជាតិប្រមាណ៤០% នៃតម្រូវការកៅស៊ូធម្មជាតិពិភពលោក។ ការផ្ទុះឡើង នៃវីរុសកូរ៉ូណានៅតែបន្តកាត់ផ្តាច់ខ្សែច្រវ៉ាក់ការផ្គត់ផ្គង់លើពិភពលោកដែលបានធ្វើឲ្យរោងចក្រនៅក្នុងប្រទេសចិនបើកដំណើរការវិញក្នុងល្បឿនយឺតជាងការរំពឹងទុក។ ការកែច្នៃបានរងផលប៉ះពាល់យ៉ាងខ្លាំងដោយមានការរអាក់រអួល ចំពោះការផ្គត់ផ្គង់វត្ថុធាតុដើមសារធាតុ និងអវត្តមាននៃកម្លាំងពលកម្ម។ ការនឹកស្មានមិនដល់នៃការធ្លាក់ចុះប្រាក់ចំណូលដ៏ធំរបស់ក្រុមហ៊ុន ដោយសារធ្លាក់ចុះនៃការលក់និងកម្រិតអាជីវកម្ម។ ដើម្បីត្រៀមខ្លួនចំពោះការខាតបង់នេះ ក្រុមជាច្រើនក៏បានប្រកាសកាត់បន្ថយទំហំការងារយ៉ាងច្រើន។ ក្នុងមួយរយៈពេលខ្លីនេះ ទីផ្សារកៅស៊ូធម្មជាតិក្នុងអំឡុងពាក់កណ្តាលខែកុម្ភៈនេះ ក៏ស្ថិតក្រោមឥទ្ធិពលនៃការផ្ទុះមេរោគកូរ៉ូណាថ្មីនេះ។

២.តាមការប៉ាន់ស្មានបឋមនៅក្នុងខែមករា ឆ្នាំ២០២០ ប្រទេសចិនបានប្រើប្រាស់កៅស៊ូធម្មជាតិចំនួន៣៤១ ០០០តោន បានធ្លាក់ចុះ២៧% បើធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន។ ប្រទេសចិនរំពឹងថា នឹងប្រើប្រាស់កៅស៊ូធម្មជាតិបានត្រឹមតែចំនួន

១០៣០០០តោនប៉ុណ្ណោះ នៅក្នុងខែកុម្ភៈឆ្នាំ២០២០ នេះ គឺបានធ្លាក់ចុះ៧២% បើប្រៀបធៀបទៅនឹងខែដូចគ្នាកាលពីឆ្នាំមុន។ លើសពីនេះ ទៅទៀតក្នុងត្រីមាសទី១ ឆ្នាំ២០២០ បានព្យាករថា ការប្រើប្រាស់កៅស៊ូធម្មជាតិក្នុងប្រទេសចិនបានធ្លាក់៣៤%។ក្នុងឆ្នាំ២០២០ ប្រទេសឥណ្ឌាបានកាត់បន្ថយការប្រើប្រាស់កៅស៊ូធម្មជាតិក្នុងស្រុកពី១,៣លានតោនទៅ ១,២លានតោន។

៣.ឥទ្ធិពលប្រេងឆៅប្រាក់យ៉េនជប៉ុននិងរូបិយប័ណ្ណរបស់ប្រទេសនាំចេញកៅស៊ូធម្មជាតិទៅលើថ្លៃកៅស៊ូបានចុះខ្សោយក្នុងសប្តាហ៍ទី១ នៃខែកុម្ភៈនេះ ដោយសារតែការព្រួយបារម្ភអំពីវីរុសកូរ៉ូណាដែលជះឥទ្ធិពលទៅលើសេដ្ឋកិច្ច។

៤.នៅពេលដែលថ្លៃកៅស៊ូចុះទាបពេក "ក្នុងលក្ខខណ្ឌលក់ច្រើន (Oversold Condition)" បានធ្វើឲ្យវិនិយោគិនស្រពិលដោយឱកាសតែមួយគត់គឺធ្វើការទិញចរចា។ វិធីសាស្ត្របែបនេះបានទប់ស្កាត់ថ្លៃមិនឱ្យធ្លាក់ចុះបន្ថែមទៀតនិងជួយឱ្យមានការងើបឡើងវិញជាបន្តបន្ទាប់។ ការស្ទុះងើបឡើងវិញនៃថ្លៃកៅស៊ូក្នុងសប្តាហ៍ទី១នៃខែកុម្ភៈភាគច្រើនបានមកពីការទិញការចរចាដែលស្ថិតក្នុងលក្ខខណ្ឌលក់ច្រើន។

៥.បណ្តាប្រទេសផលិតកៅស៊ូធម្មជាតិបានផ្គត់ផ្គង់ទាប ដោយសារតែ ដល់រដូវការសម្រាកចៀកដែលចាប់ផ្តើមពីចុងខែមករា-ដើមខែកុម្ភៈ។ ការផ្គត់ផ្គង់ទាបនេះ បានធ្វើឲ្យទីផ្សារដែលមានការធ្លាក់ចុះយ៉ាងខ្លាំងនោះងើបឡើងវិញផងដែរ។

ការថយចុះចំនួនករណីឆ្លងវីរុសកូរ៉ូណានៅក្នុងប្រទេសចិន និងការរំពឹងទុកសម្រាប់គោលនយោបាយរបស់ប្រទេចិន និងបណ្តាប្រទេសនៅទ្វីអាស៊ី បានជួយឲ្យឈប់បារម្ភអំពីការប៉ះពាល់សេដ្ឋកិច្ចដែលបណ្តាលមកពីការរាលដាលនៃជំងឺនេះ។ ក្នុងជំហាននៃការចាប់ផ្តើមកិច្ចព្រមព្រៀងពាណិជ្ជកម្មដែលបានចុះហត្ថលេខារវាងអាម៉េរិកនិងចិន បានបង្ហាញថាចិនបានរួចពន្ធលើមុខទំនិញចំនួន៦៩៦មុខដើម្បីនាំចូលសហរដ្ឋអាម៉េរិក បន្ទាប់ពីការសងសឹកតម្លើងពន្ធគ្នាទៅវិញទៅមក ហើយចំនុចវិជ្ជមាននេះ បានជួយជំរុញឲ្យមានទុកចិត្តគ្នាពាណិជ្ជកម្មឡើងវិញ។

## វិធានការពង្រឹងដើម្បីទ្រទ្រង់ ឧស្សាហកម្មកៅស៊ូធម្មជាតិ

*ឯកសារយោង៖ www.thehindubusinessline.com*
*ប្រែសម្រួលដោយកញ្ញា **ថូ ស្រីស***

ឧស្សាហកម្មកៅស៊ូធម្មជាតិត្រូវបានពិនិត្យឡើងវិញជាបន្ទាន់ ដើម្បីបង្កើតគំនិតផ្តួចផ្តើមថ្មីៗជាច្រើនក្នុងការដោះស្រាយនូវបញ្ហាដែលទាក់ទងនឹងផលិតកម្ម គុណភាព និងលទ្ធភាពដែលអាចសម្របខ្លួនបាន។

លោក **KM Mammen** ប្រធានសមាគមអ្នកផលិតសំបកកង់យានយន្តនិងជានាយកគ្រប់គ្រងក្រុមហ៊ុន MRF Ltd បានស្នើបង្កើតយុទ្ធសាស្ត្រទុនបម្រុងសម្រាប់កៅស៊ូធម្មជាតិ ការអភិវឌ្ឍតំបន់ដាំកៅស៊ូចម្រុះ ក្លូនកៅស៊ូថ្មី និងការពិសោធន៍ទៅតាមសាកវប្បកម្មកៅស៊ូតាមសៃនេទិច។

លោកបានបន្ថែមទៀតថា ការកើនឡើងនៃសីតុណ្ហភាព ភាពរាំងស្ងួតឬភ្លៀងធ្លាក់ខ្លាំងកំពុងតែជះឥទ្ធិពលដល់ទិន្នផលកៅស៊ូនិងបង្កឱ្យមានការផ្ទុះជំងឺនៅក្នុងចម្ការកៅស៊ូនៅទូទាំងពិភពលោក។

លោកក៏បានលើកឡើងក្នុងសុន្ទរកថាពិធីសម្ពោធ នៃកិច្ចប្រជុំលើកទី៥ ស្តីអំពីកៅស៊ូឥណ្ឌា (IRM: the India Rubber Meet) ថាលទ្ធភាពដែលសម្របខ្លួនបានរបស់កៅស៊ូធម្មជាតិបានក្លាយទៅជាបញ្ហាប្រឈមដ៏ធំមួយ ខណៈឧស្សាហកម្មក្នុងស្រុកដែលផលិតបានតែពាក់កណ្តាលនៃតម្រូវការរបស់ខ្លួន ជាមូលហេតុនាំឱ្យមានការនាំចូលកៅស៊ូទ្រង់ទ្រាយធំ។ កិច្ចប្រជុំរយៈពេល២ថ្ងៃនេះ បានផ្តោតលើប្រធានបទ *“Rubber Resurgence Through Innovation”* ដើម្បីជាក់មកពិភាក្សាអំពីបញ្ហាប្រឈមក្នុងវិស័យនេះ។

## យុទ្ធសាស្ត្របម្រុងទុននៅក្នុងប្រទេសឥណ្ឌា

លោកបានសង្កត់ធ្ងន់លើភាពចាំបាច់ក្នុងការស្វែងរកជម្រើសក្នុងតំបន់មិនប្រពៃណីដូចជាឥណ្ឌាខាងជើងឈៀងខាងលិចដែលចាំបាច់ត្រូវបង្កើតក្លូនកៅស៊ូថ្មីដើម្បីទប់ទល់នឹងលក្ខខណ្ឌអាកាសធាតុកាន់តែធ្ងន់ធ្ងរបាន និង បន្តពិសោធន៍តាមសាកវប្បកម្មកៅស៊ូតាមសៃនេទិច។

ការបង្កើតយុទ្ធសាស្ត្របម្រុងទុនសម្រាប់កៅស៊ូធម្មជាតិក្នុងប្រទេសឥណ្ឌាស្មើនឹងទុន នៃការប្រើប្រាស់យ៉ាងហោចណាស់មួយខែ និងអាចក្លាយជាផ្លូវវែងឆ្ងាយមួយក្នុងការកាត់បន្ថយភាពមិនច្បាស់លាស់នៃស្ថេរភាពថ្លៃក្នុងទីផ្សារនិងធានាមិនឲ្យមានការរំខានពីខាងក្រៅ ដោយកាត់បន្ថយការនាំចូលកៅស៊ូឲ្យបានច្រើនក្នុងរដូវផលិត។ប្រទេសចិនបានរក្សាទុនបម្រុងសម្រាប់យុទ្ធសាស្ត្រកៅស៊ូធម្មជាតិនេះរួចហើយដែរ។

លោកបានបន្តថា ភាពតានតានតឹងលើតម្រូវការផលិតផលថ្មីដូចជា ធាតុផ្សំសបកកង់យានយន្តបានតម្រូវឲ្យកៅស៊ូធម្មជាតិគុណភាពប្រសើរជាមុន ដោយសារតែកៅស៊ូធម្មជាតិគឺជាវត្ថុធាតុដើមស្នូលដើម្បីសន្សំសំចៃក្នុងការកែច្នៃ។ ឧស្សាហកម្មសំបកកង់យានយន្ត គឺជាអ្នកប្រើប្រាស់កៅស៊ូធម្មជាតិធំជាងគេនៅក្នុងប្រទេសដែលមានចំនួនប្រមាណពី ៧០ - ៧៥%។

លោក Sawa Dhanania ប្រធានក្រុមប្រឹក្សាកៅស៊ូយល់ថាការធ្លាក់ចុះថ្លៃកៅស៊ូកំពុងប្រឈមនឹងនិរន្តរភាពនៃការដាំដុះកៅស៊ូ។ បំណែងផ្សេងទៀតនៃខ្សែចង្វាក់ថ្លៃកៅស៊ូក៏កំពុងបញ្ហាប្រឈមបញ្ហាមួយចំនួនមានការប្រកួតប្រជែងជាសកលកាកសំណល់គ្មានរបាំងពន្ធ និងឧបសគ្គបច្ចេកវិទ្យាជាដើម។

## *ការធ្លាក់ចុះនៅក្នុងវិស័យ*

លោក Sawar Dhanania បន្តថា ការនាំចូលកៅស៊ូច្រើនពេកនិងផលិតផលសំខាន់ៗដូចជាសំបកកង់យានយន្តនិងកៅស៊ូសំយោគគឺជាក្តីបារម្ភដ៏ធំ។ លោកក៏បានណែនាំឱ្យឧស្សាហកម្មប្រកាន់យកនូវបច្ចេកវិទ្យាទំនើប និងការថ្លឹងថ្លែងពីចំណាយដើម្បីបង្រួមបញ្ហានៃធ្លាក់ចុះនេះ៕

# ទំព័រស្រាវជ្រាវ

## ជំងឺក្រៀមខ្មៅកន្ទុយស្លឹក
## Colletotrichum Leaf Disease

*រៀបចំដោយ៖ នាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ*

### ១. លក្ខណៈទូទៅ

ជំងឺក្រៀមខ្មៅកន្ទុយស្លឹក *(Collectotrichum leaf disease)* មានកើតនៅប្រទេសដាំកៅស៊ូជាច្រើន តាមកម្រិតធ្ងន់ឬស្រាលខុសៗគ្នា។ ជំងឺនេះរាតត្បាតលើស្លឹកកូនកៅស៊ូ និងកើតលើស្លឹកលាស់ថ្មីនៃដើមកៅស៊ូពេញវ័យក្រោយពេលរដូវជ្រុះស្លឹក។ ជំងឺនេះកើតពេញមួយឆ្នាំ ហើយកើតខ្លាំងជាងគេនៅពេលចាប់ផ្តើមអាកាសធាតុសើមដែលធ្វើឱ្យស្លឹកជ្រុះច្រើនចំពោះក្លូនងាយទទួលរងជំងឺ។ ជំងឺនេះ មានសភាពធ្ងន់ធ្ងរនៅពេលស្លឹកជ្រុះលើកទីពីរគឺអាស្រ័យលើក្លូនងាយទទួលរងជំងឺដោយផ្សិតនិងលក្ខខណ្ឌអាកាសធាតុនៅពេលស្លឹកលាស់ជាថ្មីឡើងវិញ។ ជំងឺនេះកើតឡើងតាមឆ្នាំ ហើយវាក៏បានបាត់ទៅវិញនៅអំឡុងពេលខ្យល់បក់ពីទិសនិរតីទៅទិសឥសានដែលជាទូទៅ វាអាចកើតឡើងនៅលើថ្នាលបណ្តុះកូនកៅស៊ូនិងនៅលើកូនកៅស៊ូមិនទាន់ពេញវ័យ ។





### ២. ភាពបង្កជំងឺ

ជំងឺ *Collectotrichum* បណ្តាលមកពីផ្សិត *Collectotrichum gloeosporioides (peuz.) Saee*។ សីតុណ្ហភាពដែលអំណោយផលដល់ការលូតលាស់ និងរាតត្បាតនៃជំងឺក្នុងចន្លោះ២៦-៣២$^0$C និងអតិបរមា២៨$^0$C។ ដំណុះស្ព័រនឹងថយចុះភ្លាមៗខណៈគេដាក់នៅហាលក្តៅនិងកំដៅកាំរស្មីស្វាយអ៊ុលត្រាក្នុងរយៈពេលខ្លី។ កម្រិតសំណើម ៩៩% ជីវិតរស់នៅនិងការលូតលាស់របស់ស្ព័រ (spore) បានកាត់បន្ថយ៥០% ប្រៀបធៀបទៅនឹងសំណើម១០០%។ *Collectotrichum gloeosporioides* នៃ *Hevea* មានបម្រែបម្រួលយ៉ាងខ្លាំងក្នុងការលូតលាស់លក្ខណៈរូបសាស្ត្រសមត្ថភាពនៃការបំបែកស្ព័រ និងការបាត់បង់សមត្ថភាពរាតត្បាតរបស់វា។ ប្រភេទរុក្ខជាតិច្រើនជាង១៥០ប្រភេទឈើផ្សេងៗទៀតក៏រងនូវជំងឺផ្សិតនេះផងដែរដូចជា៖ ស្វាយ កាហ្វេ ជាដើម។

## ៣. រោគសញ្ញា

សញ្ញាជំងឺច្រើនកើតលើស្លឹកខ្ចីដែលមានអាយុក្រោម១០ថ្ងៃ។ ជំងឺចាប់ផ្តើមដំបូងនៅលើចុងស្លឹកបន្ទាប់មករាលដាលកាន់តែធំឡើងរហូតធ្វើឱ្យស្លឹកជ្រុះ។



បើសិនជំងឺកើតលើស្លឹកចាស់ចាប់ពី១០ថ្ងៃឡើងស្លឹកមិនជ្រុះទេ ប៉ុន្តែវាបន្សល់ទុកនូវស្នាមខ្មៅខូងនៅលើស្លឹកធ្វើឱ្យស្លឹកបាក់ ហើយស្លឹកជ្រុះច្រើនជាបន្តបន្ទាប់រហូតដល់ងាប់ត្រួយនិងមែក។



នៅពេលស្លឹកមិនទាន់ចាស់ទទួលរងដោយផ្សិតតាមធម្មតាភាពធន់នៃបាហនិក (host) ការពារមិនឱ្យមានគ្រោះមហន្តរាយខ្លាំង គ្រាន់តែធ្វើឱ្យស្លឹកមានស្នាមអុច ពណ៌ត្នោតជាច្រើន ព័ទ្ធជុំវិញដោយរង្វង់ពណ៌លឿង។ នៅពេលស្នាមអុចលេចចេញកាន់តែច្រើន ផ្សិតធ្វើឱ្យមែកឈើតូច ធំ ងាប់បន្តិចម្តងៗ ហើយងាប់ដល់ដើមទាំងស្រុងនៅពេលមានជំងឺកាន់តែខ្លាំងឡើង ជាពិសេស នៅតំបន់ខ្ពស់ ឬតំបន់មានសំណើមខ្លាំង។



## ៤. ការពារនិងព្យាបាល

ប្រើប្រាស់ក្លូនដែលមានធន់ទ្រាំដូចជា៖RRIC 100, RRIC130, PB217, PB260, RRIM600។ យើងត្រូវធ្វើការដាក់ជីបំប៉នដល់ដើមកៅស៊ូដែលរៀបនឹងចេញស្លឹក ដើម្បីឲ្យដើមកៅស៊ូមានកំលាំងក្នុងការជំរុញការដុះស្លឹកថ្មីលឿន។ នៅលើថ្នាលបណ្តុះកូនគួរតែបាញ់ថ្នាំការពារជំងឺក្រៀមខ្មៅកន្ទុយស្លឹកតាមការណែនាំដូចខាងក្រោម៖ ប្រើថ្នាំឌីតាន (Dithane-M45) កម្រិត 0.5-1% ចំនួន២គ.ក្រ/ហ.ត ឬប្រើកាបិនដាស៊ីម (Carbendazim) កម្រិត 0.2-0.3% /សប្តាហ៍ម្តងឬប្រើManeb, Zineb កម្រិត 0.3-0.5% ៕

# ការសម្អាតឡូត៍និងការធ្វើផ្លូវភ្លើងក្នុងចម្ការកៅស៊ូ

*រៀបចំដោយ៖ នាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ*

កៅស៊ូគឺជាដំណាំកសិឧស្សាហកម្មរយៈពេលវែងដែលមានប្រសិទ្ធភាពសេដ្ឋកិច្ច២៥ឆ្នាំ។ ការថែទាំ គឺត្រូវតែអនុវត្តឱ្យបានត្រឹមត្រូវទៅតាមបទដ្ឋានបច្ចេកទេស ក្នុងនោះការសម្អាតក្នុងឡូត៍កៅស៊ូនិងការធ្វើផ្លូវភ្លើងដើម្បីបង្ការនិងការពារភ្លើងឆេះក្នុងចម្ការកៅស៊ូ ប្រសិនបើ កើតមានឡើងវាបណ្តាលឱ្យខូចសំបកដែលជាទុនសំខាន់បំផុតជាងគេក្នុងការប្រមូលផល។ ដើម្បីទប់ស្កាត់បញ្ហានេះ យើងត្រូវមានវិធានការចម្បងៗក្នុងការបង្ការទប់ស្កាត់និងពន្លត់អគ្គិភ័យដូចខាងក្រោម៖

## ១.ការធ្វើផ្លូវបែងចែកឡូត៍និងការធ្វើផ្លូវភ្លើងក្នុងចម្ការកៅស៊ូ

ផ្លូវគឺកត្តាមួយសំខាន់សម្រាប់ការដឹកជញ្ជូនផ្សេងៗនិងកិច្ចប្រតិបត្តិការទប់ស្កាត់រាល់សកម្មភាពទាំងឡាយណាដែលកើតមានឡើងជាយថាហេតុនៅក្នុងរដូវប្រាំង (ភ្លើងឆេះ) ផងដែរ។ ក្នុងចម្ការកៅស៊ូគ្រួសារនិងចម្ការកៅស៊ូកសិ-ឧស្សាហកម្មចាំបាច់ត្រូវមានការបែងចែកឡូត៍កៅស៊ូដោយក្នុងមួយឡូត៍មានផ្ទៃដី១០០ហិកតាចែកចេញជាបួនប្លុក(២៥ហិកតា/ប្លុក) ហើយក្នុងមួយឡូត៍គេត្រូវធ្វើផ្លូវចំនួន៨ គឺផ្លូវទទឹងថ្ងៃចំនួន៣ និងផ្លូវបណ្តោយថ្ងៃចំនួន៥ ដែលមានឈ្មោះដូចខាងក្រោម៖

- ផ្លូវ២៥០ឬផ្លូវប៉ោតរាន (ចំនួន២) ដែលមានទទឹង៦ម៉ែត្រជាផ្លូវសំខាន់បំផុត ក្នុងការដឹកជញ្ជូនទឹកជ័រពីក្នុងឡូត៍។
- ផ្លូវ៥០០(ចំនួន២)គឺជាផ្លូវ ដែលបែងចែកឡូត៍ជា៤ប្លុក ដែលមានទទឹង ៦ម៉ែត្រ។ ផ្លូវ ១ ០០០ (ចំនួន៤) គឺធ្វើដើម្បីព័ទ្ធជុំវិញ
- ក្នុងមួយឡូត៍គឺកំណត់ដោយប្រវែង១ ០០០ ម៉ែត្រស្មើនឹង១គីឡូម៉ែត្រ ផ្លូវនេះមានទទឹងរបស់វាពី ១០ ទៅ ១២ម៉ែត្រ។

ជាទូទៅ ផ្លូវភ្លើងត្រូវបានធ្វើនៅចន្លោះរងកៅស៊ូគឺនៅចំកណ្តាលនៃផ្លូវ១០០០ និង ផ្លូវ ២៥០ និងពាក់កណ្តាលផ្លូវ៥០០និងផ្លូវ២៥០។ផ្លូវភ្លើងធ្វើសម្រាប់បោសសម្អាតស្លឹកហើយដុតដើម្បីការពារភ្លើងឆេះដោយប្រការណាមួយនៅក្នុងពេលស្លឹកកៅស៊ូជ្រុះ។ គួរធ្វើប៉មដែលមានកម្ពស់ខ្ពស់សម្រាប់ឱ្យអ្នកយាមមើលឃើញបានឆ្ងាយ។ចំពោះចម្ការកៅស៊ូគ្រួសារត្រូវសម្អាតតាមជាយឡូត៍កៅស៊ូដែលនៅជាប់ព្រៃជាប់ចម្ការដំណាំដំទៃឬភូមិរបស់កសិករត្រូវជម្រះឱ្យបានស្អាតធ្វើជាផ្លូវភ្លើងប្រវែង៥ម៉ែត្រពីជួរដើមកៅស៊ូរួចបោសប្រមូលស្លឹកកៅស៊ូឬសំរាមស្មៅឬរុក្ខជាតិដែលបានជម្រះ)និងដុតឱ្យបានស្អាតបង្ការអគ្គិភ័យ ដែលអាចកើតមានដោយការបោះកន្ទុយបារីឬដោយយថាហេតុផ្សេងៗ។

## ២.ការរៀបចំរចនាសម្ព័ន្ធចាត់ចែងសម្រាប់ទប់ស្កាត់អគ្គិភ័យ

ដើម្បីកសាងប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យឱ្យបានល្អនៅទីកន្លែងដែលខ្លួនបានគ្រប់គ្រងនៅតាមចម្ការកៅស៊ូ ភូមិ រោងចក្រនិងការិយាល័យ ពិសេស

ចម្ការកៅស៊ូកសិឧស្សាហកម្មត្រូវរៀបចំរចនាសម្ព័ន្ធចាត់ចែង៖ ផ្នែកដឹកនាំ ក្រុមជំនួយ និងក្រុមយាមល្បាត។

### ក. ផ្នែកដឹកនាំ

ភារៈកិច្ចជាក់ស្តែងរបស់ផ្នែកនេះ គឺលើកគម្រោងបង្ការដោយមានទាំងគូសសម្គាល់លើផែនទី ចុះណែនាំហើយប្រគល់ភារៈកិច្ចដល់ថ្នាក់នៅក្រោមឱវាតឱ្យអនុវត្តកិច្ចបង្ការបានសមស្របតាមបច្ចេក-ទេសដោយត្រួតពិនិត្យ តាមដានសកម្មភាពការងារឱ្យបានល្អ។

### ខ. ក្រុមជំនួយ

ក្រុមជំនួយមានផ្នែកគមនាគមន៍ក្រុមបង្ការ និងពន្លត់។ ផ្នែកនេះមានភារៈកិច្ចចាត់ឱ្យរថយន្តដឹកទឹកជ័រទាំងអស់ដាក់ទឹកត្រៀមក្នុងស៊ីទែនជាប់ជានិច្ច នៅពេលសម្រាកនិងត្រៀមរថយន្តមួយគ្រឿងទៀតសម្រាប់ដឹកក្រុមពន្លត់ និងកម្មករទៅពន្លត់ភ្លើងឱ្យទាន់ពេលវេលានៅពេលដែលមានអគ្គិភ័យកើតមានឡើង។ ក្រុមបង្ការនិងពន្លត់ភ្លើងគឺជាកម្មករទាំងអស់ ទាំងអ្នកដាំដុះទាំងអ្នកចៀរជ័រ ដែលត្រូវត្រៀមឱ្យបានគ្រប់គ្រាន់នូវឧបករណ៍ពន្លត់ភ្លើងដូចជា៖ ប្រើអំបោសសាង ប៉ោតទឹក កាំបិត...។ល។

### គ. ក្រុមយាមល្បាត

ផ្នែកដឹកនាំត្រូវរៀបចំចាត់តាំងឱ្យមានក្រុមយាមល្បាតនៅតាមឡូត៍ចម្ការកៅស៊ូ ដែលខ្លួនគ្រប់គ្រង។ មួយក្រុមៗត្រូវមានសមាជិកយ៉ាងតិច២នាក់។

## ៣. ចម្ការកៅស៊ូមិនទាន់ឱ្យផល

ជាទូទៅការជ្រុះស្លឹករបស់ដើមកៅស៊ូគឺចាប់ពីខែមករាដល់ពាក់កណ្តាលខែមីនាដោយប្រែប្រួលពេលវេលាទៅតាមក្លូននីមួយៗហើយរយៈពេលជ្រុះស្លឹកប្រហែលពី១០-១៥ថ្ងៃ រួចចាប់ផ្តើមដុះស្លឹកថ្មីឡើងវិញ។ ចម្ការឬឡូត៍កៅស៊ូមិនទាន់ឱ្យផលដែលគ្មានដំណាំចន្លោះរងត្រូវវែករងជម្រះស្មៅសងខាងដើមកៅស៊ូជាបង់ (band) ឱ្យបានម្ខាង១ម៉ែត្រពីគល់ដើមកៅស៊ូ ហើយក្នុង១០ចន្លោះរងត្រូវជម្រះស្មៅមួយចន្លោះរងឱ្យដល់ដីបានស្អាតធ្វើជាផ្លូវភ្លើង។ ព្រៃដែលដុះកណ្តាលរងផ្សេងទៀតចាំបាច់ត្រូវកាប់ឱ្យបានទាបដោយទុកកម្ពស់ស្មៅ ឬព្រៃមិនឱ្យខ្ពស់ជាង១០ស.មពីដីដូចក្នុងឡូត៍កៅស៊ូផ្តល់ផលដែរ។

ក្នុងចម្ការឬឡូត៍កៅស៊ូមិនទាន់ឱ្យផលដែលមានកាក់សំណល់ដំណាំចន្លោះរងត្រូវជម្រះឱ្យបានស្អាតទាំងអស់ដោយប្រមូលកាកសំណល់ដើមដែលបេះផលរួចដាក់ចំកណ្តាលរងជាពំនូកតូចៗដាច់ពីគ្នា ហើយក្នុង១០ចន្លោះរងជម្រះឱ្យដល់ដី មួយចន្លោះរងបានស្អាតធ្វើជាផ្លូវភ្លើង។

## ៤. ចំពោះចម្ការកៅស៊ូឱ្យផល

### ក. កាប់ព្រៃចន្លោះរងនិងតាមរងកៅស៊ូ

ការកាប់ព្រៃសម្អាតក្នុងឡូត៍ គឺជាកត្តាមួយសំខាន់សម្រាប់ចម្ការកៅស៊ូនីមួយៗ ជាពិសេសនៅក្នុងរដូវប្រាំង។ នៅខែសីហា-កញ្ញា-តុលា ការកាប់ព្រៃត្រូវបានចាប់ផ្តើមកាប់ម្តងទៀត កន្លែងខ្លះលើកទី២, កន្លែងខ្លះទៀតលើកទី៣ ក៏ប៉ុន្តែត្រូវឱ្យអាទិភាពចំពោះកន្លែង ដែលមានបញ្ហាប្រឈមមុខហានិភ័យ (ទិសខ្យល់ តំបន់ជាប់វាល ព្រៃ និងចម្ការបោះបង់ចោល..)។ ដូច្នោះ ការកាប់ព្រៃសម្អាតឡូត៍ត្រូវធ្វើ

ឱ្យចប់សព្វគ្រប់ក្នុងខែតុលា។



*ការកាប់ព្រៃចន្លោះរងក្នុងឡូត៍កៅស៊ូ*

## ខ. ការសម្អាតស្លឹកក្នុងឡូត៍កៅស៊ូ

ស្លឹកកៅស៊ូចាប់ផ្តើមជ្រុះនៅក្នុងកំឡុងខែមករាដល់ពាក់កណ្តាលខែមីនាជារដូវរងារ(សីតុណ្ហភាពចុះត្រជាក់) ហើយជាទូទៅស្លឹកវាជ្រុះមានរយៈ-ពេល១០-១៥ថ្ងៃ បន្ទាប់មក វាក៏ចាប់ផ្តើមដុះស្លឹកឡើងវិញ។ ចំពោះដើមកៅស៊ូនៅក្មេង (យុវកៅស៊ូ) ការជ្រុះស្លឹកចាប់ផ្តើមពីផ្នែកខាងលើមុន ចំណែកឯដើមកៅស៊ូចាស់ការជ្រុះស្លឹកពីផ្នែកខាងក្រោមមុន។ ការសម្អាតស្លឹកក្នុងឡូត៍កៅស៊ូអាចធ្វើតាមរបៀបផ្សេងៗគ្នាទៅតាមទីកន្លែង និងតំបន់ដែលគេនិយមប្រើប្រាស់។ របៀបសម្អាតស្លឹកក្នុងឡូត៍មានដូចជា៖ ការបោះប្រមូលនឹងអំបោសឬអំបោសសាងឬម៉ាស៊ីនកែច្នៃផ្លុំស្លឹកកៅស៊ូដោយខ្យល់។ បន្ទាប់ពី ធ្វើការបោសសម្អាតស្លឹកកៅស៊ូជ្រុះដាក់តាមកណ្តាលរងកៅស៊ូ ដោយអង្គន់វាជាពំនូកតូចៗរួចរាល់ហើយក៏ធ្វើការដុតស្លឹក។



*ការបោសស្លឹកកៅស៊ូ*



*ការផ្លុំស្លឹកកៅស៊ូដោយម៉ាស៊ីន*

## គ. ការដុតស្លឹកកៅស៊ូ

ការដុតស្លឹកកៅស៊ូតាមចន្លោះរងពុំមែនជាទង្វើល្អប្រសើរឡើយព្រោះវាធ្វើឱ្យខូចដីនិងងាប់ពពួកមីក្រូសរីរាង្គ ដែលជាអ្នកជួយសម្រួលធ្វើឱ្យដីមានជីជាតិល្អ។ ផ្ទុយទៅវិញ ប្រសិនបើប្រមូលស្លឹកកៅស៊ូដាក់ឱ្យនៅចំកណ្តាលចន្លោះរង ហើយទុកឱ្យពុករលួយតាមធម្មជាតិនោះស្លឹកទាំងនេះនឹងក្លាយទៅជាជីធម្មជាតិដ៏ល្អប្រសើរសម្រាប់ដើមកៅស៊ូ។តាមបទពិសោធន៍ កន្លងមកការរក្សាស្លឹកកៅស៊ូឱ្យពុករលួយតាមលក្ខណៈធម្មជាតិបានបង្កឱ្យមានអគ្គិភ័យផងដែរ ដើម្បីជៀសវាងបញ្ហានេះ ស្លឹកកៅស៊ូដែលបានជ្រុះចាំបាច់ត្រូវដុតចោលដោយអនុវត្តតាមបច្ចេកទេសដូចខាងក្រោម៖

❖ ប្រមូលស្លឹកកៅស៊ូដាក់ឱ្យនៅចំកណ្តាលចន្លោះរងហើយផ្តាច់ជាកងៗដោយមួយកង់ៗប្រវែង២៥ម៉ែត្រ.យ៉ាងច្រើន

❖ ដុតស្លឹកមួយកងរំលងមួយកង់ដោយដុតពីក្បាលកង់ដែលបិតនៅក្រោមខ្យល់រួចបន្ទាប់មកដុតកងដែលនៅសល់ឱ្យទាល់តែអស់

❖ ពេលវេលាដុតត្រូវអនុវត្តពីព្រឹកព្រលឹមរហូតដល់ត្រឹមម៉ោង៩ព្រឹក។មិនគួរដុតស្លឹកកៅស៊ូក្រោយម៉ោង៩ព្រឹក ព្រោះស្លឹកកៅស៊ូអាចស្ងួតល្អងាយនឹងឆេះខ្លាំងដែលអាចពិបាកក្នុងការគ្រប់គ្រង។ហាមដាច់ខាតដុតស្លឹកនៅពេលរសៀលព្រោះអាចនាំឱ្យបង្កមានអគ្គិភ័យនៅពេលយប់

❖ ឃ្លាំមើលឱ្យបានហ្មត់ចត់ក្នុងពេលដុតដើម្បីចៀសវាងផ្កាភ្លើងហើរបណ្តាលឱ្យឆេះកន្លែងដទៃ

ទៀត។ ក្រោយពេលឈប់ដុតត្រូវត្រួតពិនិត្យនិងធានាឱ្យភ្លើងរលត់១០០ភាគរយ

❖ ការដុតស្លឹកកៅស៊ូធ្វើឡើងជាបីលើកគឺ៖

- លើកទី១ពេលជ្រុះស្លឹកបានប្រមាណ៣០%
- លើកទី២ពេលជ្រុះស្លឹកបានប្រមាណ៦០%
- លើកទី៣ពេលជ្រុះស្លឹកបានប្រមាណ១០០%

ជៀសវាងដាច់ខាតការដុតតែមួយដងនៅពេលស្លឹកជ្រុះ១០០ភាគរយពីព្រោះពេលនោះស្លឹកកៅស៊ូដែលប្រមូលផ្តុំមានកម្រាស់ខ្ពស់អាចឱ្យភ្លើងឆេះខ្លាំងនាំឱ្យអន្តរាយដល់ដើមកៅស៊ូដែលនៅជិត និងមិនអាចទប់ស្កាត់ការពារការរាលដាលបាន។



*ការបោសប្រមូលស្លឹកកៅស៊ូដាក់កណ្តាលរង*



*ការដុតស្លឹកកៅស៊ូតាមចន្លោះរង*

## ៥.គោលការណ៍និងវិធានការសម្រាប់ទប់ស្កាត់អគ្គិភ័យ

### ក. គោលការណ៍

នៅពេលអ្នកណាម្នាក់បានឃើញភ្លើងឆេះត្រូវអនុវត្តគោលការណ៍៧ចំណុច ដូចខាងក្រោម៖

1. លេខឡូតិ៍
2. ខាងក្នុងឬខាងក្រៅឡូតិ៍
3. ទិសខ្យល់
4. ចំណុចកើត ជើង ត្បូង លិច កើត
5. តើផ្លូវណាមួយអាចងាយស្រួលក្នុងការដឹកជញ្ជូនកម្មករ,ទឹក(សម្ភារៈអគ្គិភ័យ) ដើម្បីពន្លត់ភ្លើង
6. តើកម្មករប៉ុន្មាននាក់តម្រូវការ?
7. តម្រូវការសម្ភារៈប៉ុន្មាន ? អ្វីខ្លះ ?

### ខ. វិធានការ

យើងត្រូវមានវិធានការការពារភ្លើងឆេះដូចខាងក្រោម៖

- ប្រសិនភ្លើងមានទ្រង់ទ្រាយតូចយើងគួរតែពន្លត់វាតែម្តង
- ប្រសិនភ្លើងមានទ្រង់ទ្រាយធំមិនត្រូវឱ្យបុគ្គលណាម្នាក់ពន្លត់ដោយផ្ទាល់ទេ វាអាចបង្ករឱ្យមានគ្រោះថ្នាក់។ នៅឱ្យឆ្ងាយពីភ្លើងចម្ងាយ២០ម និងនាំគ្នាធ្វើផ្លូវភ្លើងកាត់វាកុំឱ្យវាឆេះឆ្លងរាលដាលដោយប្រមូលស្លឹក ស្មៅ កម្ទេចកម្ទីស្ងួតៗព័ទ្ធជុំវិញភ្លើង បើអាចធ្វើបានដាក់ទឹកស្រោចវារឹតតែល្អ
- ការធ្វើផ្លូវភ្លើងស្កាត់ឱ្យបានលឿននៅពេលភ្លើងកំពុងឆេះ គឺជាទង្វើរដ៏ត្រឹមត្រូវមួយដើម្បីត្រួតពិនិត្យការវិវត្តរបស់ភ្លើងរហូតដល់វាថយចុះ។ ពេលភ្លើងថយនៅតិចត្រូវពន្លត់វាដោយទឹក
- លំហាត់អនុវត្តផ្ទាល់ត្រូវរៀបចំនៅចុងខែធ្នូ និងដើមខែមករា ក្នុងចម្ការជាមួយប្រធានក្រុម, អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើផ្នែកទប់ស្កាត់ពន្លត់អគ្គិភ័យនេះតែម្តង
- នៅដើមខែមករាត្រូវធ្វើផ្លូវភ្លើងជុំវិញឡូតិ៍ឱ្យហើយរួចដុតឱ្យបានល្អ ដើម្បីការពារភ្លើងឆេះដែលរាលដាលពីកន្លែងដទៃ (ផ្កាភ្លើងហើរតាមខ្យល់) និងមានពេលវេលាគ្រប់គ្រាន់សម្រាប់តាមដាន និងដើរល្បាតក្នុងចម្ការ

• ត្រូវធ្វើប៉មយាមឱ្យបានខ្ពស់ពី៣ទៅ៥កន្លែង ដែលយើងចង់បានដើម្បីងាយស្រួលពិនិត្យមើលទៅទីឆ្ងាយ

• ដើម្បីងាយស្រួលដើរល្បាតក្នុងចម្ការកៅស៊ូ ត្រូវបែងចែកជាតំបន់ឬអនុតំបន់។ តាមតំបន់ឬអនុតំបន់ត្រូវមានក្តារខៀនសម្រាប់ឱ្យដើរល្បាតចុះហត្ថលេខាដើម្បីទុកឱ្យអ្នកទទួលខុសត្រូវប្រចាំថ្ងៃៗត្រួតពិនិត្យមើលសកម្មភាពការងាររបស់ពួកគេ។

## ៦. ការព្យាបាលដើមកៅស៊ូដែលត្រូវភ្លើងឆេះ

ការព្យាបាលដើមកៅស៊ូដែលត្រូវភ្លើងឆេះ ត្រូវ អនុវត្តន៍ដូចខាងក្រោម៖

❖ ត្រូវលាបជាបន្ទាន់នូវល្បាយកំបោរស៥% ឱ្យបានកម្ពស់ ២ម.ពីដីទាំងដើមមិនទាន់ឱ្យផល។ ដើមផ្តល់ផលរួចត្រូវផ្អាកចៀជ័របណ្តោះអាសន្នក្នុងករណីភ្លើងឆេះធ្ងន់ធ្ងរ

❖ ប្រសិនបើមានការខូចខាតដោយផ្នែកៗត្រូវកោសសំបកដែលងាប់ចេញរួចលាបថ្នាំព្យាបាល

❖ ករណីដើមកៅស៊ូឆេះងាប់គួរតែរំលំដើមយក

❖ ចេញពីចម្ការដើម្បីកាពារកុំឱ្យពុកដើមដែលនាំឱ្យបង្កជម្ងឺឆ្លងដល់ដើមល្អដែលនៅជិត ចំពោះដើមកៅស៊ូដែលឆេះធ្ងន់ធ្ងរត្រូវព្យាបាលឱ្យបានសមស្របតាមលក្ខណៈបច្ចេកទេស ដោយប្រើប្រាស់ថ្នាំព្យាបាលរបួសសំបកដូចជា៖ ប៉េត្រូឡាទុម វ៉ាស៊ីលិន (ខ្លាញ់គោ) Nufarm ឬពួក Wound dressing ដទៃទៀត

❖ គួរធ្វើកំណត់ហេតុទុកក្នុងប្រវត្តិរូបចម្ការឬឡូត៍និងរាយការណ៍ជាបន្ទាន់តាមលំដាប់ថ្នាក់ដោយបញ្ជាក់ឱ្យច្បាស់ពីឡូត៍ ផ្ទៃដី ពូជ (ក្លូន) និងចំនួនដើមដែលបានឆេះ៕



*ការព្យាបាលដើមកៅស៊ូដោយល្បាយកំបោរបន្ទាប់ពីភ្លើង*

## ឯកសារយោង


1. *សៀវភៅបច្ចេកទេសកៅស៊ូសម្រាប់កសិករកៅស៊ូគ្រួសារនៅប្រទេសភីលីពីន(E.A. ALCALA, 2000 manual for rubber smallholder , Philippine)*

2. *អគ្គនាយកដ្ឋានកៅស៊ូ, ស្តីពីដំណាំកៅស៊ូ (ដាំដុះថែទាំកែច្នៃ) ឆ្នាំ១៩៩៩*

3. *អូនសុវណ្ណ៖ ការយកផលទឹកជ័រនិងគ្រប់គ្រង ឆ្នាំ២០១៧។*

# និន្នាការតម្លៃនិងស្ថិតិកៅស៊ូធម្មជាតិតាមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ

## តារាងទី១៖ តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅតាមបណ្តាស្រុក ប្រចាំសប្តាហ៍ ខែកុម្ភៈ ឆ្នាំ២០២០

| ល.រ | ខេត្ត | សប្តាហ៍ទី ១ | | | | | | សប្តាហ៍ទី ២ | | | | | | សប្តាហ៍ទី ៣ | | | | | | សប្តាហ៍ទី ៤ | | | | | | តម្លៃមធ្យមខែ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | ជ័រកក |
| | | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | រ/គ.ក្រ |
| ១ | កំពង់ចាម | 4,800 | 1.17 | ↓ 100 | 2,100 | 0.51 | ↓ 200 | 4,800 | 1.17 | → 0 | 2,100 | 0.51 | → 0 | 4,800 | 1.17 | → 0 | 2,100 | 0.51 | → 0 | 4,900 | 1.20 | ↑ 100 | 2,000 | 0.49 | ↓ 100 | 4,825 | 2075 |
| ២ | ត្បូងឃ្មុំ | 4,800 | 1.17 | ↓ 100 | 2,100 | 0.51 | ↓ 200 | 4,800 | 1.17 | → 0 | 2,100 | 0.51 | → 0 | 4,800 | 1.17 | → 0 | 2,100 | 0.51 | → 0 | 4,800 | 1.17 | → 0 | 2,000 | 0.49 | ↓ 100 | 4,800 | 2075 |
| ៣ | កំពង់ធំ | 4,600 | 1.12 | → 0 | 2,300 | 0.56 | → 0 | 4,600 | 1.12 | → 0 | 2,300 | 0.56 | → 0 | 4,600 | 1.12 | → 0 | 2,300 | 0.56 | → 0 | 4,600 | 1.12 | → 0 | 2,300 | 0.56 | → 0 | 4,600 | 2300 |
| ៤ | រតនគិរី | 4,900 | 1.19 | → 0 | 2,500 | 0.61 | → 0 | 4,800 | 1.17 | → 0 | 2,200 | 0.54 | ↓ 300 | 4,800 | 1.17 | → 0 | 2,200 | 0.54 | → 0 | 4,300 | 1.05 | ↓ 500 | 2,000 | 0.49 | ↓ 200 | 4,700 | 2225 |
| ៥ | ក្រចេះ | 4,700 | 1.15 | ↑ 50 | 2,650 | 0.65 | ↑ 100 | 4,650 | 1.13 | ↓ 50 | 2,550 | 0.62 | ↓ 100 | 4,650 | 1.14 | → 0 | 2,550 | 0.62 | → 0 | 4,600 | 1.12 | ↓ 50 | 2,500 | 0.61 | ↓ 50 | 4,650 | 2563 |
| ៦ | មណ្ឌលគិរី | | | | 2,100 | 0.51 | ↓ 200 | | | | 2,300 | 0.56 | ↑ 200 | | | | 2,300 | 0.56 | → 0 | | | | 2,200 | 0.54 | ↓ 100 | | 2225 |
| តម្លៃមធ្យម | | 4,760 | 1.16 | ↓ 30 | 2,292 | 0.56 | ↓ 83 | 4,730 | 1.15 | ↓ 30 | 2,258 | 0.55 | ↓ 33 | 4,730 | 1.15 | → 0 | 2,258 | 0.55 | → 0 | 4,640 | 1.13 | ↓ 90 | 2,167 | 0.53 | ↓ 92 | 4,715 | 2,244 |
| អត្រាប្តូរប្រាក់ធនាគារជាតិនៃកម្ពុជា | | | 4,101 | | | | | | 4,098 | | | | | | 4,096 | | | | | | 4,094 | | | | | | |

បញ្ជាក់៖

*ប្រភព: ពីអ្នកប្រមូលទិញតាមតំបន់*

*ទឹកជ័រ: គិតជាស្ងួត (DRC)*

*ជ័រកក: DRC ≅ 50%*

ស្ថានភាពទិញជ័រកៅស៊ូគ្រួសារតាមតំបន់នានាប្រចាំខែកុម្ភៈនេះ មានតម្លៃចន្លោះពី៤ ៦០០ ទៅ ៤ ៨២៥រ/គ.ក្រ សម្រាប់ជ័រស្ងួត និង២ ០៧៥ - ២ ៥៦៣រ/គ.ក្រ សម្រាប់ជ័រកក។ ជារួម តម្លៃទិញ-លក់ជ័រកៅស៊ូគ្រួសារបានកើនឡើងពី១០០រ/គ.ក្រ អាស្រ័យតាមតំបន់ បើធៀបនឹងខែមុន។

# ស្ថានភាពធុរកិច្ចផលិតផលជ័រកៅស៊ូស្ងួតប្រចាំខែកុម្ភៈ ឆ្នាំ២០២០

| ល.រ | ចម្ការកៅស៊ូ | កុម្ភៈ ២០១៩ | | | | | | កុម្ភៈ ២០២០ | | | | | | ធៀបខែមុន | | | | ធៀបរយៈពេលដូចគ្នានៅឆ្នាំមុន | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | បរិមាណ | | តម្លៃមធ្យម | | បរិមាណ | | | | តម្លៃមធ្យម | | | |
| | | បរិមាណ(តោន) | | ទឹកប្រាក់($) | | តម្លៃមធ្យម($/តោន) | | បរិមាណ(តោន) | | ទឹកប្រាក់($) | | តម្លៃមធ្យម($/តោន) | | ខែនេះ | | ខែនេះ | | ខែនេះ | | ដល់ខែនេះ | | ខែនេះ | | ដល់ខែនេះ | |
| | | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | តោន | % | $/តោន | % | តោន | % | តោន | % | $/តោន | % | $/តោន | % |
| I. កៅស៊ូកសិ-ឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | | |
| ក | ចម្ការកៅស៊ូកសិ-ឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | |
| 1 | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | | 0 | | 0 | 0 | 0 | 15 | 15 | 14.500 | 14.500 | 967 | 967 | 15 | 100,00 | 967 | 100,00 | 15 | 100 | 15 | 100 | 967 | 100 | 967 | 100 |
| 2 | ក្រុមហ៊ុនសុភក្តិនីកា អ៊ីនវេសមេន គ្រុប | 1.219 | 3.147 | 1.600.258 | 4.004.329 | 1.312 | 1.273 | 390 | 1.326 | 602.860 | 1.976.576 | 1.547 | 1.490 | -547 | -58,41 | 81 | 5,52 | -830 | -68 | -1.820 | -58 | 235 | 18 | 218 | 17 |
| 3 | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | 210 | 336 | 268.170 | 432.600 | 1.277 | 1.288 | 210 | 210 | 275.940 | 275.940 | 1.314 | 1.314 | 210 | 100,00 | 1.314 | 100,00 | 0 | 0 | -126 | -38 | 37 | 3 | 27 | 2 |
| 4 | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខូអិលធីឌី | 396 | 878 | 539.002 | 1.143.968 | 1.359 | 1.303 | 515 | 797 | 815.432 | 1.227.502 | 1.585 | 1.541 | 232 | 82,31 | 125 | 8,54 | 118 | 30 | -81 | -9 | 225 | 17 | 237 | 18 |
| 5 | ក្រុមហ៊ុនស៊ីហ្វ រ៉ាប់ប៊ើ លីមីតធីត(រតនគិរី) | | 0 | | 0 | 0 | 0 | | 0 | | 0 | 0 | 0 | 0 | 0,00 | 0 | 0,00 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 6 | ក្រុមហ៊ុនស៊ីហ្វ រីសសស លីមីធីត(ស្នួល) | 168 | 714 | 203.280 | 843.780 | 1.210 | 1.182 | 513 | 945 | 677.900 | 1.282.700 | 1.322 | 1.358 | 81 | 18,66 | -78 | -5,54 | 345 | 205 | 231 | 32 | 112 | 9 | 176 | 15 |
| 7 | ក្រុមហ៊ុនឡុងស្រេងអ៊ីនធើណេស៊ិនណល | 210 | 210 | 272.580 | 272.580 | 1.298 | 1.298 | 400 | 925 | 533.400 | 1.315.125 | 1.334 | 1.422 | -125 | -23,81 | -156 | -10,44 | 190 | 90 | 715 | 340 | 36 | 3 | 124 | 10 |
| 8 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ចម្ការអណ្តូង) | | 250 | | 276.300 | 0 | 1.105 | | 230 | | 286.600 | 0 | 1.246 | -230 | 0,00 | -1.246 | 0,00 | 0 | 0 | -20 | -8 | 0 | 0 | 141 | 13 |
| 9 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ពាមជាំង) | | 100 | | 109.500 | 0 | 1.095 | | 129 | | 158.422 | 0 | 1.232 | -129 | 0,00 | -1.232 | 0,00 | 0 | 0 | 29 | 29 | 0 | 0 | 137 | 13 |
| 10 | ក្រុមហ៊ុនក្រែក(ខេមបូឌា) ខូអិលធីឌី | 840 | 1.260 | 1.072.050 | 1.594.530 | 1.276 | 1.266 | 420 | 630 | 560.700 | 875.700 | 1.335 | 1.390 | 210 | 100,00 | -165 | -11,00 | -420 | -50 | -630 | -50 | 59 | 5 | 125 | 10 |
| **សរុប ក** | | **3.044** | **6.895** | **3.955.339** | **8.677.587** | **1.299** | **1.259** | **2.462** | **5.206** | **3.480.732** | **7.413.066** | **1.414** | **1.424** | **-283** | **-10,31** | **-19** | **-1,31** | **-582** | **-19** | **-1.688** | **-24** | **114** | **9** | **165** | **13** |
| ខ | ចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ច | 4.000 | 11.800 | 5.197.692 | 14.763.353 | 1.299 | 1.251 | 4.800 | 15.000 | 6.786.817 | 21.400.683 | 1.414 | 1.427 | -5.400 | -52,94 | -19 | -1,31 | 800 | 20 | 3.200 | 27 | 114 | 9 | 176 | 14 |
| **សរុបI=ក+ខ** | | 7.044 | 18.695 | 9.153.031 | 23.440.940 | 1.299 | 1.254 | 7.262 | 20.206 | 10.267.549 | 28.813.749 | 1.414 | 1.426 | -5.683 | -43,90 | -19 | -1,31 | 218 | 3 | 1.512 | 8 | 114 | 9 | 172 | 14 |
| **II. កៅស៊ូគ្រួសារ** | | 6.000 | 17.800 | 7.796.537 | 22.267.666 | 1.299 | 1.251 | 6.600 | 21.100 | 9.331.873 | 30.106.487 | 1.414 | 1.427 | -7.900 | -54,48 | -19 | -1,31 | 600 | 10 | 3.300 | 19 | 114 | 9 | 176 | 14 |
| **សរុបI+II** | | **13.044** | **36.495** | **16.949.569** | **45.708.606** | **1.299** | **1.252** | **13.862** | **41.306** | **19.599.422** | **58.920.236** | **1.414** | **1.426** | **-13.583** | **-49,49** | **-19** | **-1,33** | **818** | **6** | **4.812** | **13** | **114** | **9** | **174** | **14** |

**បញ្ជាក់៖**

១៖ ក្នុងខែកុម្ភៈ ឆ្នាំ២០២០ បរិមាណបញ្ចេញលក់សរុបមានចំនួន១៣ ៨៦២តោន បានថយចុះចំនួន ១៣ ៥៨៣តោន(=-៤៩,៤៩%)បើធៀបនឹងខែមុន ប៉ុន្តែបានកើនឡើងចំនួន ៨១៨តោន(=៦%)បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

២. តម្លៃលក់មធ្យមក្នុងខែកុម្ភៈ ឆ្នាំ២០២០ គឺ១ ៤១៤ដុល្លារ/តោន បានថយចុះចំនួន ១៩ដុល្លារ/តោន(=-១,៣៣%)ធៀបនឹងខែមុន ប៉ុន្តែបានកើនឡើងចំនួន ១១៤ដុល្លារ/តោន(=៩%)បើធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

៣. រហូតមកដល់ខែកុម្ភៈ ឆ្នាំ២០២០ បរិមាណបញ្ចេញលក់សរុបមានចំនួន ៤១ ៣០៦តោន បានកើនឡើងចំនួន ៤ ៨១២តោន(=+១៣%)ធៀបរយៈពេលដូចគ្នាឆ្នាំ២០១៩។

៤. រហូតដល់ខែកុម្ភៈ ឆ្នាំ២០២០ តម្លៃលក់មធ្យមគឺ១ ៤២៦ដុល្លារ/តោន បានកើនឡើងចំនួន ១៧៤ដុល្លារ/តោន (=១៤%)ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៩។

ថ្ងៃ[illegible] ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ [illegible] ឆ្នាំ២០២០
អ្នកធ្វើតារាង

បានឃើញ និងឯកភាព
ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ
អគ្គនាយករង

ចាន់_វឌ្ឍនា

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ

ហ៊ិន-សារ៉ាផន

## តារាងទី៣៖ តម្លៃកៅស៊ូនៅទីផ្សារប្រទេសថៃ ប្រចាំខែកុម្ភៈ ឆ្នាំ២០២០ (ដុល្លារសហរដ្ឋអាមេរិក/តោន)

| ថ្ងៃ | កៅស៊ូសន្លឹកសំដិលដោយខ្យល់ USS *1* | | | | | | | | សន្លឹកចំហុយ | ជ័រចាន | ទឹកជ័រនៅចម្ការ |
|---|---|---|---|---|---|---|---|---|---|---|---|
| | Hat Yai | Khlong Nga | Trang | Phuket | Surat thani | Rayong | Ubonrat chatani | មធ្យម | | | |
| **3** | 1 320,48 | 1 320,48 | 1 289,04 | 1 320,48 | 1 289,04 | 1 289,04 | 1 289,04 | 1 302,56 | 1 662,86 | 1 068,96 | 1 320,48 |
| **4** | 1 314,19 | 1 304,76 | 1 289,04 | 1 311,05 | 1 289,04 | 1 289,04 | 1 289,04 | 1 298,16 | 1 663,49 | 1 068,96 | 1 314,19 |
| **5** | 1 311,05 | 1 304,76 | 1 289,04 | 1 304,76 | 1 249,74 | 1 257,60 | 1 257,60 | 1 282,12 | 1 630,79 | 1 076,82 | 1 311,68 |
| **6** | 1 257,60 | 1 257,60 | 1 241,88 | 1 257,60 | 1 255,71 | 1 241,88 | 1 226,16 | 1 248,48 | 1 519,18 | 1 037,52 | 1 289,04 |
| **7** | 1 289,04 | 1 289,04 | 1 251,31 | 1 273,32 | 1 273,32 | 1 226,16 | 1 226,16 | 1 261,06 | 1 498,12 | 1 021,80 | 1 282,75 |
| **11** | 1 263,89 | 1 257,60 | 1 241,88 | 1 257,60 | 1 273,32 | 1 226,16 | 1 226,16 | 1 249,43 | 1 515,41 | 1 037,52 | 1 281,18 |
| **12** | 1 251,31 | 1 257,60 | 1 251,31 | 1 257,60 | 1 289,04 | 1 257,60 | 1 257,60 | 1 260,43 | 1 531,13 | 1 021,80 | 1 289,04 |
| **13** | 1 295,33 | 1 289,04 | 1 257,60 | 1 257,60 | 1 279,61 | 1 248,17 | 1 257,60 | 1 269,23 | 1 509,12 | 1 006,08 | 1 289,04 |
| **14** | 1 289,04 | 1 289,04 | 1 251,31 | 1 257,60 | 1 296,90 | 1 226,16 | 1 257,60 | 1 266,72 | 1 525,78 | 1 021,80 | 1 289,04 |
| **17** | 1 289,04 | 1 289,04 | 1 257,60 | 1 257,60 | 1 296,90 | 1 226,16 | 1 257,60 | 1 267,66 | 1 515,41 | 1 021,80 | 1 257,60 |
| **18** | 1 289,04 | 1 289,04 | 1 251,31 | 1 257,60 | 1 296,90 | 1 226,16 | 1 257,60 | 1 266,72 | 1 522,32 | 1 037,52 | 1 257,60 |
| **19** | 1 296,90 | 1 289,04 | 1 257,60 | 1 257,60 | 1 296,90 | 1 226,16 | 1 257,60 | 1 268,92 | 1 092,54 | 1 320,48 | 1 351,92 |
| **20** | 1 307,90 | 1 289,04 | 1 251,31 | 1 257,60 | 1 289,04 | 1 226,16 | 1 289,04 | 1 273,01 | 1 548,11 | 1 076,82 | 1 320,48 |
| **21** | 1 367,64 | 1 351,92 | 1 289,04 | 1 289,04 | 1 351,92 | 1 257,60 | 1 320,48 | 1 318,28 | 1 573,89 | 1 112,03 | 1 351,92 |
| **24** | 1 380,22 | 1 367,64 | 1 304,76 | 1 320,48 | 1 373,93 | 1 257,60 | 1 320,48 | 1 332,11 | 1 596,52 | 1 131,84 | 1 358,21 |
| **25** | 1 377,07 | 1 367,64 | 1 320,48 | 1 320,48 | 1 367,64 | 1 257,60 | 1 320,48 | 1 333,06 | 1 611,30 | 1 108,26 | 1 320,48 |
| **26** | 1 351,92 | 1 351,92 | 1 336,20 | 1 351,92 | 1 358,21 | 1 257,60 | 1 320,48 | 1 327,08 | 1 588,98 | 1 100,40 | 1 336,20 |
| **27** | 1 367,64 | 1 367,64 | 1 367,64 | 1 367,64 | 1 367,64 | 1 257,60 | 1 320,48 | 1 345,32 | 1 619,79 | 1 084,68 | 1 315,14 |
| **28** | 1 351,92 | 1 351,92 | 1 351,92 | 1 351,92 | 1 358,21 | 1 289,04 | 1 320,48 | 1 339,34 | 1 600,92 | 1 119,26 | 1 367,64 |
| **មធ្យម** | ***1 314,27*** | ***1 309,72*** | ***1 281,59*** | ***1 291,03*** | ***1 308,05*** | ***1 249,66*** | ***1 277,46*** | ***1 289,98*** | ***1 543,46*** | ***1 077,60*** | ***1 310,72*** |
| **អតិបរមា** | ***1 380,22*** | ***1 367,64*** | ***1 367,64*** | ***1 367,64*** | ***1 373,93*** | ***1 289,04*** | ***1 320,48*** | ***1 345,32*** | ***1 663,49*** | ***1 320,48*** | ***1 367,64*** |
| **អប្បរមា** | ***1 251,31*** | ***1 257,60*** | ***1 241,88*** | ***1 257,60*** | ***1 249,74*** | ***1 226,16*** | ***1 226,16*** | ***1 248,48*** | ***1 092,54*** | ***1 006,08*** | ***1 257,60*** |

កំណត់សំគាល់៖ នេះជាតម្លៃកៅស៊ូក្នុងស្រុកបានមកពីសមាគមន៍កៅស៊ូថៃ ដែលបានអង្កេតយ៉ាងតិច ២-៥សមាជិក/ថ្ងៃ

*1* USS = Un-Smoked Sheets (កៅស៊ូសន្លឹកសំដិលដោយខ្យល់)

## តារាងទី៤៖ តម្លៃកៅស៊ូស្តង់ដារម៉ាឡេស៊ី SMR/FOB ប្រចាំខែកុម្ភៈ ឆ្នាំ២០២០ (ដុល្លារសហរដ្ឋអាម៉េរិក/តោន)

| កុម្ភៈ | SMR CV | SMR L | SMR 5 | SMR GP | SMR 10 | SMR 20 |
|---|---|---|---|---|---|---|
| **3** | 1 840,00 | 1 815,00 | 1 330,00 | 1 322,50 | 1 305,50 | 1 300,50 |
| **4** | 1 816,50 | 1 792,00 | 1 309,50 | 1 302,50 | 1 285,00 | 1 280,00 |
| **5** | 1 846,50 | 1 822,00 | 1 344,00 | 1 336,50 | 1 319,00 | 1 314,00 |
| **6** | 1 871,00 | 1 846,50 | 1 354,50 | 1 347,00 | 1 329,50 | 1 325,00 |
| **7** | 1 891,00 | 1 866,50 | 1 353,50 | 1 346,50 | 1 329,00 | 1 324,00 |
| **10** | 1 904,00 | 1 879,50 | 1 359,50 | 1 352,00 | 1 335,00 | 1 330,00 |
| **11** | 1 931,50 | 1 907,00 | 1 374,50 | 1 367,0 | 1 350,00 | 1 345,00 |
| **12** | 1 957,50 | 1 933,00 | 1 380,00 | 1 372,50 | 1 355,50 | 1 350,50 |
| **13** | 1 961,00 | 1 936,50 | 1 387,50 | 1 380,00 | 1 362,50 | 1 358,00 |
| **14** | 1 950,00 | 1 925,50 | 1 378,00 | 1 370,50 | 1 353,50 | 1 348,50 |
| **17** | 1 936,00 | 1 911,50 | 1 392,50 | 1 385,50 | 1 368,00 | 1 363,00 |
| **18** | 1 935,50 | 1 911,00 | 1 391,50 | 1 384,00 | 1 367,00 | 1 362,00 |
| **19** | 1 931,00 | 1 906,50 | 1 391,00 | 1 383,50 | 1 366,50 | 1 361,50 |
| **20** | 1 928,00 | 1 904,00 | 1 396,00 | 1 388,50 | 1 371,50 | 1 366,50 |
| **21** | 1 925,50 | 1 901,00 | 1 404,50 | 1 397,50 | 1 380,50 | 1 375,50 |
| **24** | 1 904,00 | 1 880,00 | 1 371,50 | 1 364,00 | 1 347,50 | 1 342,50 |
| **25** | 1 901,50 | 1 877,50 | 1 373,00 | 1 366,00 | 1 349,00 | 1 344,00 |
| **26** | 1 910,50 | 1 886,50 | 1 394,50 | 1 387,00 | 1 370,50 | 1 365,50 |
| **27** | 1 904,50 | 1 880,50 | 1 383,00 | 1 376,00 | 1 359,00 | 1 354,00 |
| **28** | 1 892,00 | 1 868,00 | 1 352,00 | 1 345,00 | 1 328,00 | 1 323,00 |
| **មធ្យម** | ***1 906,90*** | ***1 882,50*** | ***1 371,00*** | ***1 363,70*** | ***1 346,60*** | ***1 341,50*** |
| **អតិបរមា** | ***1 961,00*** | ***1 936,50*** | ***1 404,50*** | ***1 397,50*** | ***1 380,50*** | ***1 375,50*** |
| **អប្បបរមា** | ***1 816,50*** | ***1 792,00*** | ***1 309,50*** | ***1 302,50*** | ***1 285,00*** | ***1 280,00*** |




- តម្លៃកៅស៊ូស្តង់ដារម៉ាឡេស៊ីលេខ១០ (SMR 10) បានធ្លាក់ដល់១ ៣៤៦,៦០ដុល្លារអាម៉េរិក/តោន ក្នុងខែកុម្ភៈ ឆ្នាំ២០២០ បើធៀបទៅនឹងខែមករា ឆ្នាំ២០២០ ដែលមានតម្លៃ ១ ៤៧៤,៦០ដុល្លារអាម៉េរិក/តោន ដូចនេះ សន្ទស្សន៍តម្លៃ បានថយចុះ១,០៩ មានន័យថា តម្លៃកៅស៊ូខែកុម្ភៈ ឆ្នាំ២០១២០ ធ្លាក់ ចុះដល់៩% ។

SMR = Standard Malaysian Rubber (កៅស៊ូស្តង់ដារម៉ាឡេស៊ី ), FOB = Fee-on-Board (ថ្លៃទំនិញដឹកដល់កប៉ាល់)

## តារាងទី៥៖ តម្លៃកៅស៊ូស្តង់ដារវៀតណាម SVR/FOB ប្រចាំខែកុម្ភៈ ឆ្នាំ២០២០ (ដុល្លារសហរដ្ឋអាម៉េរិក/តោន)

| កុម្ភៈ | SVR CV | SVR L | SVR 5 | SVR GP | SVR 10 | SVR 20 |
|---|---|---|---|---|---|---|
| 4 | 1 762,00 | 1 738,20 | 1 270,20 | 1 263,40 | 1 246,50 | 1 241,60 |
| 5 | 1 791,10 | 1 767,30 | 1 303,70 | 1 296,40 | 1 279,40 | 1 274,60 |
| 6 | 1 814,90 | 1 791,10 | 1 313,90 | 1 306,60 | 1 289,60 | 1 285,30 |
| 7 | 1 834,30 | 1 810,50 | 1 312,90 | 1 306,10 | 1 289,10 | 1 284,30 |
| 10 | 1 846,90 | 1 823,10 | 1 318,70 | 1 311,40 | 1 295,00 | 1 290,10 |
| 11 | 1 873,60 | 1 849,80 | 1 333,30 | 1 326,00 | 1 309,50 | 1 304,70 |
| 13 | 1902,20 | 1 878,40 | 1 345,90 | 1 338,60 | 1 321,60 | 1 317,30 |
| 14 | 1 891,50 | 1 867,70 | 1 336,70 | 1 329,40 | 1 312,90 | 1 308,00 |
| 17 | 1 877,90 | 1 854,20 | 1 350,70 | 1 343,90 | 1 327,00 | 1 322,10 |
| 18 | 1 877,40 | 1 853,70 | 1 349,80 | 1 342,50 | 1 326,00 | 1 321,10 |
| 19 | 1 873,10 | 1 849,30 | 1 349,30 | 1 342,00 | 1 325,50 | 1 320,70 |
| 20 | 1 870,20 | 1 846,90 | 1 354,10 | 1 346,80 | 1 330,40 | 1 325,50 |
| 21 | 1 867,70 | 1 844,00 | 1 362,40 | 1 355,60 | 1 339,10 | 1 334,20 |
| 25 | 1 844,50 | 1 821,20 | 1 331,80 | 1 325,00 | 1 308,50 | 1 303,70 |
| 26 | 1 853,20 | 1 829,90 | 1 352,70 | 1 345,40 | 1 329,40 | 1 324,50 |
| 27 | 1 847,40 | 1 824,10 | 1 341,50 | 1 334,70 | 1 318,20 | 1 313,40 |
| 28 | 1 835,20 | 1 812,00 | 1 311,40 | 1 304,70 | 1 288,20 | 1 283,30 |
| **មធ្យម** | ***1 850,80*** | ***1 827,10*** | ***1 331,70*** | ***1 324,60*** | ***1 308,00*** | ***1 303,20*** |
| **អតិបរមា** | ***1 902,20*** | ***1 878,40*** | ***1 362,40*** | ***1 355,60*** | ***1 339,10*** | ***1 334,20*** |
| **អប្បបរមា** | ***1 762,00*** | ***1 738,20*** | ***1 270,20*** | ***1 263,40*** | ***1 246,50*** | ***1 241,60*** |




- តម្លៃកៅស៊ូស្តង់ដារវៀតណាមលេខ១០ (SMR 10) បានធ្លាក់ដល់១ ៣០៨,០០ដុល្លារអាម៉េរិក/តោន ក្នុងខែកុម្ភៈ ឆ្នាំ២០២០ បើធៀបទៅនឹងខែមករា ឆ្នាំ២០២០ ដែលមានតម្លៃ ១ ៤៦១,៩៧ដុល្លារអាម៉េរិក/តោន ដូចនេះ សន្ទស្សន៍តម្លៃ បានថយចុះ១,១១ មានន័យថា តម្លៃកៅស៊ូខែកុម្ភៈ ឆ្នាំ២០២០ ធ្លាក់ចុះដល់ ១១%។

SVR = Standard Vietnam Rubber (កៅស៊ូស្តង់ដារវៀតណាម),

FOB = Free-on-Board (ថ្លៃទំនិញដឹកដល់កប៉ាល់)

## តារាងទី៦៖ តម្លៃកៅស៊ូធម្មជាតិចេញដោយ Association of Natural Rubber Producing Countries ប្រចាំខែកុម្ភៈ ឆ្នាំ២០២០ (ដុល្លារ/តោន)

| កុម្ភៈ | Latex 60% | RSS | | TSR | |
|---|---|---|---|---|---|
| | ម៉ាឡេស៊ី(៤) | បាងកក RSS 3(២) | កូតាយ៉ាម RSS 4(៣) | បាងកក TSR 20(២) | គូឡាឡាំពួរ SMR 20(១) |
| 3 | 1 074,00 | 1 510,10 | 1 860,00 | 1 373,80 | 1 300,50 |
| 4 | 1 060,40 | 1 500,90 | 1 851,00 | 1 342,70 | 1 280,00 |
| 5 | 1 078,30 | 1 498,40 | 1 869,50 | 1 340,90 | 1 314,00 |
| 6 | 1 093,00 | 1 512,30 | 1 873,50 | 1 346,60 | 1 325,00 |
| 7 | 1 105,20 | 1 511,70 | 1 880,50 | 1 348,10 | 1 324,00 |
| 10 | 1 113,20 | - | 1 895,00 | - | 1 330,00 |
| 11 | 1 129,30 | 1 519,60 | 1 907,50 | 1 356,10 | 1 345,00 |
| 12 | 1 145,20 | 1 530,70 | 1 923,50 | 1 365,40 | 1 350,50 |
| 13 | 1 147,30 | 1 537,90 | 1 936,50 | 1 374,20 | 1 358,00 |
| 14 | 1 140,40 | 1 535,70 | 1 931,00 | 1 378,50 | 1 348,50 |
| 17 | 1 132,20 | 1 555,40 | 1 919,00 | 1 382,20 | 1 363,00 |
| 18 | 1 131,80 | 1 573,70 | 1 911,00 | 1 392,80 | 1 362,00 |
| 19 | 1 129,30 | 1 592,00 | 1 914,50 | 1 401,20 | 1 361,50 |
| 20 | 1 127,90 | 1 599,10 | 1 904,50 | 1 396,40 | 1 366,50 |
| 21 | 1 125,90 | 1 594,20 | 1 899,50 | 1 391,80 | 1 375,50 |
| 24 | 1 113,50 | 1 601,30 | 1 892,50 | 1 382,20 | 1 342,50 |
| 25 | 1 111,60 | 1 616,60 | 1 879,00 | 1 376,60 | 1 344,00 |
| 26 | 1 117,60 | 1 606,50 | 1 978,50 | 1 374,30 | 1 365,50 |
| 27 | 1 113,60 | 1 624,40 | 1 882,00 | 1 398,00 | 1 354,00 |
| 28 | 1 106,30 | 1 632,60 | 1 885,00 | 1 405,00 | 1 323,00 |
| មធ្យម | *1 114,80* | *1 560,68* | *1 899,67* | *1 375,09* | *1 341,60* |
| អតិបរមា | *1 147,30* | *1 632,60* | *1 978,50* | *1 405,00* | *1 375,50* |
| អប្បរមា | *1 060,40* | *1 498,40* | *1 851,00* | *1 340,90* | *1 280,00* |

***សំគាល់៖***

*(១) ថ្លៃបវន្តផ្ទុកលើនាវាកំណត់ដោយអ្នកទិញនៅល្ងាចម៉ោង៥:០០*

*(២) ថ្លៃបវន្តផ្ទុកលើនាវាកំណត់ដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូថៃ*

*(៣) ថ្លៃជាមធ្យមកំណត់ដោយទីផ្សារឥណ្ឌា (ដែលទាក់ទងនឹងថ្លៃទីផ្សារក្នុងស្រុកនិងមិនគិតថ្លៃពន្ធ ឫថ្លៃផ្សេង)*

*(៤) ថ្លៃកំណត់ដោយអ្នកទិញដែលបានរាយការណ៍ជាផ្លូវការ ដោយក្រុមប្រឹក្សាកៅស៊ូម៉ាឡេស៊ី*

***ពាក្យកាត់៖***

**1*TSR = Technical Specified Rubber (កៅស៊ូបញ្ជាក់គុណភាពតាមបច្ចេកទេស)*

**2*RSS = Ribbed Smoked Sheets (កៅស៊ូសន្លឹកសម្ងួតដោយផ្សែង)*

**3*Latex 60% (ទឹកជ័រខាប់៦០%)*

**4*SMR = Standard Malaysia Rubber (កៅស៊ូស្តង់ដារប្រទេសម៉ាឡេស៊ី)*

**5*STR = Standard Thai Rubber (កៅស៊ូស្តង់ដារប្រទេសថៃ)*

## តារាងទី៧៖ តម្លៃកៅស៊ូសន្លឹកលេខ៣ (RSS3) នៅលើទីផ្សារហ៊ឺន TOCOM (ដុល្លារសហរដ្ឋអាមេរិក/តោន)

| កិច្ចសន្យាប្រចាំខែ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| កញ្ញា ១៩ | កុម្ភៈ ២០ | តុលា ១៩ | ឧសភា ២០ | វិច្ឆិកា ១៩ | មេសា ២០ | ធ្នូ ១៩ | ឧសភា ២០ | មករា ១៩ | មិថុនា ២០ | កុម្ភៈ ២០ | កក្កដា ២០ |
| 2 | 1 466,10 | 1 | 1 428,30 | 1 | 1 548,90 | 2 | 1 703,70 | 6 | 1 821,60 | 3 | 1 557,00 |
| 3 | 1 458,90 | 2 | 1 404,90 | 5 | 1 601,10 | 3 | 1 701,00 | 7 | 1 811,70 | 4 | 1 572,30 |
| 4 | 1 497,60 | 3 | 1 400,40 | 6 | 1 605,60 | 4 | 1 698,30 | 8 | 1 823,40 | 5 | 1 575,00 |
| 5 | 1 491,30 | 4 | 1 413,90 | 7 | 1 610,10 | 5 | 1 782,00 | 9 | 1 809,00 | 6 | 1 606,50 |
| 6 | 1 485,00 | 7 | 1 403,10 | 8 | 1 595,70 | 6 | 1 773,00 | 10 | 1 812,60 | 7 | 1 576,80 |
| 9 | 1 485,00 | 8 | 1 431,00 | 11 | 1 606,50 | 9 | 1 775,70 | 14 | 1 870,20 | 10 | 1 593,90 |
| 10 | 1 521,00 | 9 | 1 422,00 | 12 | 1 620,00 | 10 | 1 785,60 | 15 | 1 845,00 | 12 | 1 611,00 |
| 11 | 1 519,20 | 10 | 1 440,00 | 13 | 1 621,80 | 11 | 1 783,80 | 16 | 1 863,00 | 13 | 1 638,00 |
| 12 | 1 526,40 | 11 | 1 470,60 | 16 | 1 640,70 | 12 | 1 790,10 | 17 | 1 855,80 | 14 | 1 646,10 |
| 13 | 1 535,40 | 15 | 1 471,50 | 17 | 1 638,00 | 13 | 1 798,20 | 20 | 1 812,60 | 17 | 1 660,50 |
| 17 | 1 557,00 | 16 | 1 463,40 | 18 | 1 640,70 | 16 | 1 808,10 | 21 | 1 737,00 | 18 | 1 681,20 |
| 18 | 1 532,70 | 17 | 1 474,20 | 19 | 1 643,40 | 17 | 1 795,50 | 22 | 1 722,60 | 19 | 1 677,60 |
| 19 | 1 528,20 | 18 | 1 494,00 | 20 | 1 674,90 | 18 | 1 746,00 | 23 | 1 719,00 | 20 | 1 679,40 |
| 20 | 1 499,40 | 21 | 1 492,20 | 23 | 1 680,30 | 19 | 1 739,70 | 24 | 1 639,80 | 21 | 1 705,50 |
| 24 | 1 512,90 | 23 | 1 533,60 | 24 | 1 683,00 | 20 | 1 742,40 | 27 | 1 566,00 | 25 | 1 664,10 |
| 25 | 1 497,60 | 24 | 1 519,20 | 25 | 1 665,00 | 23 | 1 755,00 | 28 | 1 603,80 | 26 | 1 640,70 |
| 26 | 1 496,70 | 25 | 1 514,70 | 26 | 1 667,70 | 24 | 1 784,70 | 29 | 1 668,60 | 27 | 1 618,20 |
| 27 | 1 453,50 | 28 | 1 503,90 | 27 | 1 662,30 | 25 | 1 761,30 | 30 | 1 611,00 | 28 | 1 544,40 |
| 30 | 1 440,00 | 29 | 1 503,00 | 30 | 1 651,50 | 26 | 1 764,00 | | | | |
| | | 30 | 1 528,20 | | | 27 | 1 778,40 | | | | |
| | | 31 | 1 541,70 | | | 30 | 1 77950 | | | | |

*ប្រភព៖ ព្រឹត្តិបត្រ ANRPC ប្រចាំខែកុម្ភៈ ឆ្នាំ២០២០*

*អត្រា៖ ១យ៉េន =០,០០៩០ដុល្លារ*

## តារាងទី៨៖ តម្លៃកៅស៊ូសន្លឹកលេខ៣ (RSS3) នៅលើទីផ្សារហ៊ីនសៀងហៃ (ដុល្លារសហរដ្ឋអាម៉េរិក/តោន)

| កិច្ចសន្យាប្រចាំខែ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| សីហា ១៩ | មករា ២០ | តុលា១៩ | មករា ២០ | វិច្ឆិកា ១៩ | ឧសភា ២០ | ធ្នូ ១៩ | ឧសភា ២០ | មករា ២០ | ឧសភា ២០ | កុម្ភៈ ២០ | ឧសភា ២០ |
| 2 | 1 698,48 | 8 | 1 648,08 | 1 | 1 733,04 | 2 | 1 824,48 | 2 | 1 866,96 | 3 | 1 566,72 |
| 3 | 1 700,64 | 9 | 1 656,72 | 4 | 1 736,64 | 3 | 1 824,48 | 3 | 1 850,40 | 4 | 1 566,72 |
| 4 | 1 728,72 | 10 | 1 662,48 | 5 | 1 764,00 | 4 | 1 835,28 | 6 | 1 869,84 | 5 | 1 617,12 |
| 5 | 1 742,40 | 11 | 1 668,96 | 6 | 1 772,64 | 5 | 1 877,76 | 7 | 1 885,68 | 6 | 1 624,32 |
| 6 | 1 735,92 | 14 | 1 679,76 | 7 | 1 775,52 | 6 | 1 905,84 | 8 | 1 910,16 | 7 | 1 627,92 |
| 9 | 1 726,56 | 15 | 1 671,84 | 8 | 1 758,96 | 9 | 1 910,16 | 9 | 1 884,96 | 10 | 1 635,84 |
| 10 | 1 602,00 | 16 | 1 664,64 | 11 | 1 753,20 | 10 | 1 908,72 | 10 | 1 445,04 | 11 | 1 650,96 |
| 11 | 1 725,12 | 17 | 1 668,24 | 12 | 1 750,32 | 11 | 1 899,36 | 13 | 1 912,32 | 12 | 1 649,52 |
| 12 | 1 720,08 | 18 | 1 681,92 | 13 | 1 766,16 | 12 | 1 905,84 | 14 | 1 914,48 | 13 | 1 650,96 |
| 16 | 1 735,20 | 21 | 1 686,96 | 14 | 1 768,32 | 13 | 1 910,16 | 15 | 1 902,24 | 14 | 1 641,60 |
| 17 | 1 745,28 | 22 | 1 704,96 | 15 | 1 761,84 | 16 | 1 886,40 | 16 | 1 896,48 | 17 | 1 668,24 |
| 18 | 1 719,36 | 23 | 1 712,16 | 18 | 1 752,48 | 17 | 1 898,64 | 17 | 1 897,20 | 18 | 1 676,16 |
| 19 | 1 713,60 | 24 | 1 702,08 | 19 | 1 766,16 | 18 | 1 895,76 | 20 | 1 866,96 | 19 | 1 675,44 |
| 20 | 1 699,20 | 25 | 1 705,68 | 20 | 1 810,80 | 19 | 1 851,84 | 21 | 1 833,84 | 20 | 1 678,32 |
| 23 | 1 723,68 | 28 | 1 700,64 | 21 | 1 831,68 | 20 | 1845,36 | 22 | 1 782,00 | 21 | 1 692,00 |
| 24 | 1 718,64 | 29 | 1 691,28 | 22 | 1 847,52 | 23 | 1 838,88 | 23 | 1 764,00 | 24 | 1 648,80 |
| 25 | 1 699,92 | 30 | 1 709,28 | 25 | 1 856,88 | 24 | 1 840,32 | | | 25 | 1 643,04 |
| 26 | 1 689,12 | 31 | 1 728,72 | 26 | 1 839,60 | 25 | 1 846,80 | | | 26 | 1 643,76 |
| 27 | 1 653,84 | | | 27 | 1 830,96 | 26 | 1 833,84 | | | 27 | 1 629,36 |
| 30 | 1 652,40 | | | 28 | 1 825,92 | 27 | 1 851,84 | | | 28 | 1 555,20 |
| | | | | 29 | 1 810,08 | 30 | 1 867,68 | | | | |
| | | | | | | 31 | 1 867,68 | | | | |

*ប្រភព៖ ព្រឹត្តិបត្រ ANRPC ប្រចាំខែកុម្ភៈ ឆ្នាំ២០២០*

*អត្រា៖ ១យ័ន =0,១៤៤ដុល្លារ*

## តារាងទី៩៖ តម្លៃកៅស៊ូ TSR 20 នៅលើទីផ្សារហ៊ុន SICOM (ដុល្លារសហរដ្ឋអាម៉េរិក/តោន)

| កិច្ចសន្យាប្រចាំខែ | | | |
|---|---|---|---|
| មករា ២០ | មេសា ២០ | កុម្ភៈ ២០ | ឧសភា ២០ |
| 2 | 1 467,00 | 3 | 1 287,00 |
| 3 | 1 465,00 | 4 | 1 329,00 |
| 6 | 1 498,00 | 5 | 1 345,00 |
| 7 | 1 514,00 | 6 | 1 343,00 |
| 8 | 1 516,00 | 7 | 1 344,00 |
| 9 | 1 491,00 | 10 | 1 344,00 |
| 10 | 1 503,00 | 12 | 1 363,00 |
| 13 | 1 555,00 | 13 | 1 362,00 |
| 14 | 1 536,00 | 14 | 1 361,00 |
| 15 | 1 535,00 | 17 | 1 379,00 |
| 16 | 1 538,00 | 18 | 1 377,00 |
| 17 | 1 533,00 | 19 | 1 373,00 |
| 20 | 1 517,00 | 20 | 1 380,00 |
| 21 | 1 487,00 | 21 | 1 379,00 |
| 22 | 1 473,00 | 25 | 1 357,00 |
| 23 | 1 441,00 | 26 | 1 335,00 |
| 27 | 1 441,00 | 27 | 1 336,00 |
| 28 | 1 352,00 | 28 | 1 281,00 |
| 29 | 1 384,00 | | |
| 30 | 1 357,00 | | |
| 31 | 1 345,00 | | |

# ស្ថានភាពនៃការវិវត្តន៍ទីផ្សារកៅស៊ូធម្មជាតិ

*ប្រភព៖ ព្រឹត្តិបត្រ ANRPC ប្រចាំខែកុម្ភៈ ២០២០*

***ប្រែសម្រួលដោយ លោក គុយ គគ្គី***

## ការវិវត្តន៍នៃទីផ្សារកៅស៊ូធម្មជាតិក្នុងអំឡុងខែមករា-កុម្ភៈ ឆ្នាំ២០២០នេះ

ភាពរំញោចនៃទីផ្សារទាំងពីរគឺ ទីផ្សារទិញលក់ភ្លាមៗនិងទីផ្សារទិញលក់តាមកិច្ចសន្យា ក្នុងអំឡុងពាក់កណ្តាលខែមករា ឆ្នាំ២០២០ បានបង្ហាញពីក្តីបារម្ភអំពីឥទ្ធិពលនៃការរីកសាយភាយរបស់មេរោគ COVID-19 ទៅលើសេដ្ឋកិច្ចពិភពលោកនិងចុក្ខវិស័យនៃការប្រើប្រាស់កៅស៊ូធម្មជាតិ។ នៅសប្តាហ៍ចុងក្រោយខែកុម្ភៈ ឆ្នាំ២០២០នេះ គឺជាសប្តាហ៍ច្របូកច្របល់ ចំពោះភាគហ៊ុនពិភពលោកនិងទំនិញពាណិជ្ជ-កម្ម ចំពេលដែលការព្រួយបារម្ភខ្លាំងលើការផ្ទុះជំងឺមេរោគថ្មីនេះបានសាយភាយជុំវិញពិភពលោក។ ទោះបីជាការចាប់ផ្តើមវាយតម្លៃទៅលើផលប៉ះពាល់នៃកំណើនសេដ្ឋកិច្ចសាកលលោកបែបនេះក៏ដោយ ក៏ម៉ូឌែលព្យាករណ៍បានបង្ហាញថា៖ កំណើនសេដ្ឋកិច្ចសាកលលោកអាចស្ថិតនៅក្រោមចំនុច២ពិន្ទុ ក្នុងឆ្នាំ២០២០នេះ។ ដោយសារតែ ឥទ្ធិពលនៃការបារម្ភពីមេរោគ COVID-19 ទីផ្សារកៅស៊ូធម្មជាតិក៏មានការចាប់អារម្មណ៍ខ្លាំងផ្អែកលើកត្តាផ្សេងៗមួយចំនួន ព្រមរាប់បញ្ចូលជាមួយកត្តារដូវកាលផ្គត់ផ្គង់ទាប។

ក្រាហ្វិកខាងក្រោមនឹងបង្ហាញពីនិន្នាការនៃតម្លៃទិញលក់តាមកិច្ចសន្យាសម្រាប់ខែមីនា ឆ្នាំ២០២០ នៅក្នុងទីផ្សារហ៊ុនសៀងហៃគិតចាប់ពីដើមខែមករា ឆ្នាំ២០២០ រហូតដល់សប្តាហ៍ដំបូង នៃខែមីនា ឆ្នាំ២០២០។

**ក្រាហ្វិកទី១៖ តម្លៃកៅស៊ូទិញលក់តាមកិច្ចសន្យាសម្រាប់ខែឧសភា ឆ្នាំ២០២០ នៅទីផ្សារហ៊ុនសៀងហៃ (យ័នតោន/តោន)**



ក្រាហ្វិតទី២នេះ នឹងបរិយាយពីនិន្នាការតម្លៃទិញលក់កៅស៊ូដុំ TSR20 តាមកិច្ចសន្យាប្រចាំថ្ងៃសម្រាប់ខែឧសភា ឆ្នាំ២០២០នេះ នៅលើទីផ្សារហ៊ុនសិង្ហបុរីចាប់ពីពាក់កណ្តាលខែមករា រហូតដល់សប្តាហ៍ទី១ នៃខែឧសភា ឆ្នាំ២០២០។

**ក្រាហ្វិកទី២៖ តម្លៃកៅស៊ូទិញលក់ដុំ TSR20 តាមកិច្ចសន្យាសម្រាប់ខែឧសភា ឆ្នាំ២០២០ នៅទីផ្សារហ៊ុនសិង្ហបុរី (ដុល្លារសហរដ្ឋអាមេរិក/១០០គីឡូក្រាម)**




ក្រាហ្វិតទី៣នេះ នឹងបរិយាយពីនិន្នាការតម្លៃទិញលក់កៅស៊ូសន្លឹកRSS3 តាមកិច្ចសន្យាប្រចាំថ្ងៃសម្រាប់ខែឧសភា ឆ្នាំ២០២០នេះ នៅលើទីផ្សារហ៊ុនតូក្យូចាប់ពីពាក់កណ្តាលខែមករា រហូតដល់សប្តាហ៍ទី១នៃខែឧសភា ឆ្នាំ២០២០។

**ក្រាហ្វិកទី៣៖ តម្លៃកៅស៊ូទិញលក់ដុំ RSS3 តាមកិច្ចសន្យាសម្រាប់ខែឧសភា ឆ្នាំ២០២០ នៅទីផ្សារហ៊ុនតូក្យូ (យ៉េន/គីឡូក្រាម)**



តម្លៃទិញលក់កៅស៊ូតាមកិច្ចសន្យាបានបង្ហាញពីនិន្នាការស្ទើរតែដូចគ្នាទាំងស្រុងក្នុងទីផ្សារហ៊ុនទាំងបីដូចជា៖ ទីផ្សារហ៊ុនសៀងហៃ សិង្ហបុរី និងតូក្យូ។ ម៉្យាងវិញទៀត តម្លៃកៅស៊ូទិញលក់តាមកិច្ចសន្យាបានកំពុងអនុឡោមតាមយ៉ាងខ្លាំងទៅនឹងភាគហ៊ុនសាកលលោកក្នុងអំឡុងពេលដែលបានតាមដាននេះ។

តម្លៃដែលបានចុះកិច្ចសន្យាប្រចាំថ្ងៃរួចនៅទីផ្សារហ៊ុនសៀងហៃ សិង្ហបុរី និងតូក្យូ ក៏បានបង្ហាញនៅលើតារាងតម្លៃទិញលក់កៅស៊ូតាមកិច្ចសន្យានៅក្នុងទីផ្សារនីមួយៗដែលមាននៅក្នុងព្រឹត្តិបត្រកៅស៊ូធម្មជាតិប្រចាំខែកុម្ភៈ ឆ្នាំ២០២០នេះ ផងដែរ។

ទីផ្សារកៅស៊ូទិញលក់ភ្លាមៗក៏បានបង្ហាញអំពីនិន្នាការស្ទើរតែដូចគ្នានឹងនិន្នាការទីផ្សារទិញលក់តាមកិច្ចសន្យាផងដែរ។ ក្រាហ្វិកទី៤នេះ នឹងបង្ហាញអំពីតម្លៃ FOB ប្រចាំថ្ងៃរបស់ កៅស៊ូ TSR20 នៅទីផ្សារបាងកក និងកៅស៊ូ SMR20 នៅទីផ្សារគួរឡាឡាំពួរ ចាប់ពីដើមខែមករា រហូតដល់ចុងខែកុម្ភៈ ឆ្នាំ២០២០នេះ។

**ក្រាហ្វិកទី៤៖ តម្លៃFOB ប្រចាំថ្ងៃរបស់កៅស៊ូ STR20 នៅទីផ្សារបាងកក និងកៅស៊ូ SMR20 នៅទីផ្សារគួឡាឡាំពួរ (ដុល្លារសហរដ្ឋអាម៉េរិក/១០០គីឡូក្រាម)**




ក្រាហ្វិកទី៥នេះ នឹងបង្ហាញអំពីនិន្នាការតម្លៃ FOB របស់កៅស៊ូ RSS3 នៅទីផ្សារបាងកក និងកៅស៊ូ RSS4 នៅទីផ្សារកូតូយ៉ាម ចាប់ដើមខែមករា រហូតដល់ចុងខែកុម្ភៈ ឆ្នាំ២០២០នេះ។ បើប្រៀបធៀបតម្លៃកៅស៊ូRSS4នៅទីផ្សារកូតូយ៉ាម និងកៅស៊ូ RSS3 នៅទីផ្សារបាងកក ក្នុងអំឡុងខែមករា-កុម្ភៈ ឆ្នាំ២០២០នេះ បានបង្ហាញថា និន្នាការតម្លៃកៅស៊ូ RSS4 មានតម្លៃខ្ពស់ជាងតម្លៃកៅស៊ូ RSS3។

### ក្រាហ្វិកទី៥៖ តម្លៃ FOB ប្រចាំថ្ងៃរបស់កៅស៊ូ RSS3 នៅទីផ្សារបាងកក និងកៅស៊ូ RSS4 នៅទីផ្សារគួឡាឡាំពួរ (ដុល្លារសហរដ្ឋអាម៉េរិក/១០០គីឡូក្រាម)




ក្រាហ្វិកទី៦នេះ នឹងបង្ហាញពីនិន្នាការថ្លៃទឹកជ័រកៅស៊ូ ៦០% ប្រចាំថ្ងៃចាប់ខែមករា ដល់ខែកុម្ភៈ ឆ្នាំ២០២០នេះ បានកើនឡើងគួរឲ្យកត់សម្គាល់ ដោយសារតែតម្រូវការប្រើប្រាស់ស្រោមដៃពេទ្យកើនឡើងខណៈពេលដែលជំងឺ COVID-19 បានផ្ទុះឡើងទូទាំងសាកលលោក។

### ក្រាហ្វិកទី៦៖ តម្លៃទឹកជ័រ ៦០% ប្រចាំថ្ងៃក្នុងស្រុកនៅទីផ្សារគួឡាឡាំពួរ (ដុល្លារសហរដ្ឋអាម៉េរិក/១០០គីឡូក្រាម)

